ខែឧសភា ២០១៨

# ការពិត និងតួលេខ ទីកន្លែងសាធារណៈ

## របាយការណ៍ស្តីពីទីកន្លែងសាធារណៈក្នុងរាជធានីភ្នំពេញ

#៣៥



សមាគមធាងត្នោត
Sahmakum Teang Tnaut. a Cambodian Urban NGO

សមាគមធាងត្នោត

Sahmakum Teang Tnaut. a Cambodian Urban NGO

**ការពិត និងតួលេខ**

ខែឧសភា ឆ្នាំ២០១៨

ឯកសារបោះពុម្ពផ្សាយស្តីអំពីបញ្ហាក្នុងទីក្រុងដោយអង្គការសមាគមធាងត្នោត (STT)

# ទីកន្លែងសាធារណៈ

# របាយការណ៍ស្តីពីទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ

# ទីកន្លែងសាធារណៈ

*របាយការណ៍ស្តីពីទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ*

**ការពិត និងតួលេខ**

*ខែឧសភា ឆ្នាំ២០១៨*

ឯកសារបោះពុម្ពផ្សាយស្តីអំពីបញ្ហាក្នុងទីក្រុង ដោយអង្គការសមាគមធាងត្នោត (STT)

សមាគមធាងត្នោត
Sahmakum Teang Tnaut. a Cambodian Urban NGO

#៣៥

## ទិដ្ឋភាពទូទៅ

ទីកន្លែងសាធារណៈដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសសម្រាប់សម្មភាពផ្សេងៗដូចជា កន្លែងសម្រាប់សម្រាកលំហែ និងកសាងទំនាក់ទំនង ក៏ដូចជាវេទិកាសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ សេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំដោយសន្តិវិធីជាដើម។ របាយការណ៍នេះរៀបរាប់លម្អិត និងបង្ហាញអំពីផែនទីទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញដើម្បីពិភាក្សាពីតួនាទីរបស់វានៅក្នុងទីក្រុង ព្រមជាមួយនឹងទស្សនៈរបស់ប្រជាពលរដ្ឋ និងដើម្បីឱ្យស្គាល់កាន់តែច្បាស់ថាតើទីកន្លែងទាំងនោះស្ថិតនៅឯណា តើទីកន្លែងទាំងនោះផ្តល់អត្ថប្រយោជន៍អ្វីខ្លះ តើនរណាខ្លះអាចប្រើប្រាស់ទីកន្លែងទាំងនោះបាន និងថាតើទីកន្លែងទាំងនោះប្រឈមនឹងការគំរាមកំហែងអ្វីខ្លះ។ របាយការណ៍នេះរៀបរាប់អំពីប្រវត្តិនិងគោលគំនិតនៃទីកន្លែងសាធារណៈ រួមមានចំណាត់ថ្នាក់តាមផ្លូវច្បាប់ និងការយល់ឃើញរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងអ្វីដែលបង្កើតបានជាទីកន្លែងសាធារណៈ។



*ទិដ្ឋភាពតាមបណ្តោយមាត់ទន្លេក្បែរព្រះបរមរាជវាំង (អង្គការសមាគមធាងត្នោតឆ្នាំ២០១៨)*

## លទ្ធផលរកឃើញសំខាន់ៗ

- *របាយការណ៍នេះរៀបរាប់លម្អិតអំពីទីកន្លែងសាធារណៈចំនួន៨៧កន្លែង នៅក្នុងរាជធានីភ្នំពេញ។*
- *ទីកន្លែងសាធារណៈចំនួន២១កន្លែង ស្ថិតនៅក្នុងខណ្ឌខាងក្រៅក្រុងចំនួន៧ (មានជ័យ សែនសុខ ដង្កោ ជ្រោយចង្វារ ច្បារអំពៅ ពោធិ៍សែនជ័យ និងព្រែកព្នៅ) និង ៦៦កន្លែងទៀត ស្ថិតនៅក្នុងខណ្ឌខាងក្នុងក្រុង (ចំការមន ដូនពេញ ៧មករា ទួលគោក និងឫស្សីកែវ)។*
- *ទីកន្លែងសាធារណៈនៅក្នុងខណ្ឌខាងក្នុងក្រុងមានក្រឡាផ្ទៃសរុបប្រមាណជា ០.៦៧ គម²។*
- *អ្នកឆ្លើយតបសម្ភាសចំនួន៨៨% បាននិយាយថាពួកគេគិតថារាជធានីភ្នំពេញត្រូវការទីកន្លែងសាធាណៈបន្ថែមទៀត និង ៩០% បាននិយាយថាទីកន្លែងសាធារណៈទាំងនោះគួរតែបង្កើតឡើងដោយរាជរដ្ឋាភិបាល។*
- *មានទីកន្លែងសាធារណៈតិចតួចណាស់នៅក្នុងខណ្ឌខាងក្រៅក្រុង ហើយប្រជាពលរដ្ឋរស់នៅតំបន់នោះបានប្រាប់អ្នកស្រាវជ្រាវតាមរយៈការស្ទង់មតិថា ដីជាទីកន្លែងសាធារណៈជាច្រើនស្ថិតនៅក្នុងបុរីដែលមានន័យថាការចូលទីកន្លែងសាធារណៈទាំងនោះត្រូវបានគ្រប់គ្រងដោយម្ចាស់បុរី។*
- *អ្នកឆ្លើយតបសម្ភាសចំនួន ១០% មានអារម្មណ៍ថាកាលពីអតីតកាល ពួកគេត្រូវបានផាត់ចេញពីទីកន្លែងសាធារណៈ។*

*"ទីកន្លែងសាធារណៈគួរតែជាកន្លែងទំនេរ និងមានទំហំធំដែលអាចឱ្យគ្រប់គ្នាធ្វើលំហាត់ប្រាណ និងទទួលបាននូវអត្ថប្រយោជន៍សុខភាពផងដែរ"* ( អ្នកចូលរួមក្នុងការពិភាក្សាក្រុម)



*មុខព្រះបរមរាជវាំងនាពេលរាត្រី (អង្គការសមាគមធាងត្នោតឆ្នាំ២០១៨)*

| | |
|---|---|
| សេចក្ដីផ្ដើម | ៤ |
| វិធីសាស្រ្ត | ៨ |
| ដែនកំណត់ | ១៣ |
| ផែនទីទី១៖ ទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ | ១៥ |
| ផែនទីទី២៖ ទីកន្លែងសាធារណៈនៃខណ្ឌខាងក្នុងរាជធានីភ្នំពេញ | ១៦ |
| ផែនទីទី៣៖ តំបន់នៃទីកន្លែងសាធារណៈនៃខណ្ឌខាងក្នុងរាជធានីភ្នំពេញ | ១៧ |
| លទ្ធផលរកឃើញសំខាន់ៗ | ១៨ |
| ក. ទីកន្លែងសាធារណៈ | ១៨ |
| ខ. ការប្រើប្រាស់ទីកន្លែងសាធារណៈ | ១៩ |
| គ. ការយល់ឃើញទាក់ទងនឹងទីកន្លែងសាធារណៈ | ២០ |
| ឃ. បញ្ហានៅទីកន្លែងសាធារណៈ | ២៤ |
| ង. ការបង្កើតទីកន្លែងសាធារណៈ | ២៥ |
| ករណីសិក្សាទី១៖ ទីលានប្រជាធិបតេយ្យត្រូវបានផ្លាស់ប្ដូរកន្លែងថ្មី | ២៦ |
| ករណីសិក្សាទី២៖ ពីសាធារណៈមកជាឯកជន | ២៧ |
| សេចក្ដីសន្និដ្ឋាន | ២៨ |
| អនុសាសន៍ | ២៨ |
| ឯកសារយោង | ២៩ |

## សេចក្ដីផ្ដើម

ការស្រាវជ្រាវស្ដីពីទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ និងការកំណត់ផែនទីទីកន្លែងទាំងនោះ គឺកម្រមានណាស់ ដូច្នេះរបាយការណ៍នេះនឹងសិក្សាទៅលើបញ្ហានេះ។ ការស្រាវជ្រាវនេះមានគោលបំណង (ក) បង្ហាញទីតាំងទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ (ខ) បង្កើនការយល់ឃើញរបស់សាធារណជនអំពីទីកន្លែងសាធារណៈ និង (គ) ផ្ដល់អនុសាសន៍នានាផ្អែកលើលទ្ធផលដែលបានរកឃើញ។ ការចាត់ថ្នាក់ដីពីដីសាធារណៈរបស់រដ្ឋដែលបានបាត់បង់ការប្រើប្រាស់ជាប្រយោជន៍សាធារណៈនាពេលថ្មីៗនេះក៏បានបង្ហាញនៅក្នុងការស្រាវជ្រាវមួយនេះផងដែរ។

កាលពីមុន ទីកន្លែងសាធារណៈដើរតួជាកន្លែងដែលប្រើប្រាស់ដោយ (ក) សាធារណជន និងសម្រាប់ជាប្រយោជន៍ដល់សាធារណជន ឬ (ខ) ប្រើប្រាស់ដោយរដ្ឋសម្រាប់ជាមធ្យោបាយដើម្បីគ្រប់គ្រងប្រជាពលរដ្ឋ[1]។ គោលគំនិតនៃ "ទ្រព្យសម្បត្តិរួម" គឺតំបន់ ធនធាន ឬអ្វីមួយដែលកាន់កាប់រួមគ្នាដែលវាទំនងជាត្រូវបានគេកំណត់ថាតើ ជាទូទៅកន្លែងណាជាកម្មសិទ្ធិឯកជន និងកន្លែងណាជាកម្មសិទ្ធិសង្គម ឬសាធារណជន[2]។ ប្រវត្តិវិទូជាច្រើនទាញការយកចិត្តទុកដាក់ទៅលើការលេចឡើងនូវស្ថាប័នរដ្ឋ ដូចជាកន្លែងសម្រាប់សម្ដែងមតិ កន្លែងសម្រាប់សកម្មភាពវប្បធម៌ និងកន្លែងសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋព្រមគ្នាជាមួយនឹងការលេចឡើងនូវទីកន្លែងសាធារណៈកាន់តែច្រើន ជាពិសេសនៅក្នុងវប្បធម៌រឹងមាំនៃលទ្ធិប្រជាធិបតេយ្យដែលមាននៅក្នុងសម័យក្រិចបុរាណផងដែរ[3]។ អ្នកនិពន្ធទាំងនេះមើលឃើញថាចំណុចចាប់ផ្ដើមសម្រាប់ទីកន្លែងសាធារណៈទាក់ទងជាមួយនឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ពីព្រោះកន្លែងទាំងនេះទំនងជាត្រូវបានផ្ដល់ជាទីកន្លែងសម្រាប់សេរីភាពក្នុងការបញ្ចេញមតិ ការរៀបចំសកម្មភាពសាធារណៈនានារបស់គណបក្ស ឬក្រុមណាមួយ និងការតវ៉ាផ្សេងៗទៀតផង។ មានទីកន្លែងសាធារណៈផ្សេងទៀត ដូចជា មហាវិថីធំៗ ដែលអាចប្រើប្រាស់ជាទីផ្សារ និងផ្លូវចូល ប៉ុន្តែរដ្ឋក៏អាចប្រើប្រាស់មហាវិថីទាំងនោះដើម្បីចល័តទ័ព និងត្រួតត្រាប្រជាពលរដ្ឋ[4]ផងដែរ។ នៅក្នុងសៀវភៅរបស់លោក ស្ព្រីងជើរ៍ (Springer) បោះពុម្ពក្នុងឆ្នាំ២០១០ ក្រោមចំណងជើងថា "របត់សេរីភាពបែបថ្មីរបស់ប្រទេសកម្ពុជា"៖ អំពើហិង្សា ការដឹកនាំរដ្ឋដោយអំណាចប្រមូលផ្ដុំ និងវិវាទកម្មលើទីកន្លែង សាធារណៈ" លើកឡើងថាទីកន្លែងសាធារណៈមានសារៈសំខាន់ខាងនយោបាយសម្រាប់ឱ្យមានការ តវ៉ាប្រឆាំងនឹងអំណាច ដែលជាទីតាំងសម្រាប់ផ្ដល់មតិត្រឡប់តាមរយៈការប្រមូលផ្ដុំ និងបាតុកម្ម។ ទីកន្លែងសាធារណៈនៅក្នុងប្រទេសកម្ពុជាខ្លះបម្រើមុខ ងារប្រជាធិបតេយ្យយ៉ាងច្បាស់ដោយជួយសម្រួលដល់ការអនុវត្តសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការ ប្រមូលផ្ដុំដោយសន្តិវិធី ដូចជាទីលានប្រជាធិបតេយ្យ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ ដែលមានទំហំ ១.២ហិចតា សម្រាប់ការធ្វើតវ៉ានានាស្របតាមច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។ ទោះបីជាតឡូវ ទីលាននេះត្រូវបានប្ដូរទីតាំងយ៉ាងណាក៏ដោយសារៈសំខាន់នៃការតវ៉ា

[1] Stanley et al, 2012. p.1104.
[2] Smith and Low, 2006.
[3] Crouch, 1981; Carr et al., 1992; Madanipour, 2003; Carmona et al., 2008
[4] Stanley et al, 2012. p.1104, 1105.

ជាសាធារណៈ សេរីភាពក្នុងការតវ៉ាដោយសន្តិវិធី និងវេទិកាសម្រាប់សម្តែងមតិដែលមិនអាចត្រូវបានគេដឹងឮ គួរត្រូវបានគេមើលឃើញថាមានសារៈសំខាន់ខ្លាំងសម្រាប់លទ្ធិប្រជាធិបតេយ្យដោយមានការចូលរួម។ ជាការសោកស្តាយ ការប្តូរទីតាំងទីលានប្រជាធិបតេយ្យ ពីកណ្តាលក្រុងទៅកាន់ភាគខាងជើងនៃរាជធានីភ្នំពេញចម្ងាយ ៤គីឡូម៉ែត្រ បានកើតឡើងព្រមគ្នាជាមួយនឹងសកម្មភាពផ្សេងទៀតដែលបាននាំឱ្យអ្នកអង្កេតការណ៍ព្រមានថាប្រទេស កម្ពុជាកំពុងតែបាត់បង់បទដ្ឋានប្រជាធិបតេយ្យ[5]។

“*អាជ្ញាធរគួរតែផ្តល់ទីកន្លែងសាធារណៈដើម្បីឱ្យប្រជាពលរដ្ឋអាចជួបជុំគ្នា និងតស៊ូមតិលើបញ្ហារបស់ពួកគេ*”(អ្នកចូលរួមក្នុងការពិភាក្សាក្រុម)។




*ទីលានប្រជាធិបតេយ្យ (អង្គការសមាគមធាងត្នោតឆ្នាំ២០១៨)*

ជាទូទៅ ទីកន្លែងសាធារណៈក្នុងរាជធានីភ្នំពេញប្រើប្រាស់តិចតួចជាទីកន្លែងជួបជុំបែបប្រជាធិបតេយ្យ វាក៏ដើរតួនាទីសំខាន់ផ្សេងទៀតដែលអាចជាកន្លែងសម្រាកលំហែ និងធ្វើលំហាត់ប្រាណផងដែរ។ នៅក្នុងឆ្នាំ២០១៥ ប្រេដលី ហ្គារ៉េត (Bradley Garret) បានសរសេរអត្ថបទមួយទាក់ទងនឹងទីក្រុងឱ្យទៅសារព័ត៌មាន ឌីហ្គាឌាន (The Guardian) ស្តីពីសារៈសំខាន់នៃទីកន្លែងសាធារណៈនិងហានិភ័យនៃឯកជនភាវូបនីយកម្មទៅលើតំបន់ទីក្រុងទូទាំងពិភពលោក[6]។ អត្ថបទរបស់គាត់បានសង្កត់ធ្ងន់ថាពហុកីឡដ្ឋានជាតិអូឡាំពិក ភ្នំពេញគឺជាឧទាហរណ៍សំខាន់មួយនៃទីកន្លែងសាធារណៈ ដែលគេអាចចូលបានដោយសេរីគ្មានការរឹតត្បិត។ ពហុកីឡដ្ឋានជាតិអូឡាំពិកផ្តល់សេវាសាធារណៈដល់រាជធានីភ្នំពេញ ជាពិសេសបំផុត គឺកន្លែងជួបជុំធ្វើលំហាត់ប្រាណនានាដូចជា ទីលានបាល់បោះ បាល់ទាត់ បាល់ទះ និងវាយកូនបាល់ ទីលានហាត់ ក្បាច់គុន ទីលានវាយប៊ូល និងទីលានជាច្រើនទៀតសម្រាប់រត់ និងដើរហាត់ប្រាណ។ ពហុកីឡដ្ឋានជាតិបើកចំហជូនសាធារណជនផងដែរ លើកលែងតែមានការប្រកួតបាល់ទាត់នៅទីនោះ។ទោះជាយ៉ាងណាក៏ដោយ ខណៈដែលកន្លែងនេះកំពុងពេញនិយមសម្រាប់សាធារណជនក្តី ហានិភ័យនៃឯកជនភាវូបនីយកម្មទីកន្លែងសាធារណៈនេះក៏មានកម្រិតខ្ពស់ណាស់ដែរ និងធ្លាប់ឃើញមាននៅកន្លែងផ្សេងក្នុងរាជធានីភ្នំពេញរួចហើយនាប៉ុន្មានឆ្នាំចុងក្រោយនេះ។ និន្នាការនោះមានភាពត្រូវគ្នាជាមួយនិន្នាការនៃឯកជនភាវូបនីយកម្មដែលត្រូវបានគេប្រសិទ្ធនាមថា “អវសានន្តនៃទីកន្លែងសាធារណៈ”[7]។ គុណវិបត្តិនៃឯកជនភាវូបនីយកម្មនៃតំបន់សាធារណៈស្ថិតនៅត្រង់ថា កន្លែងទាំងនោះអាចគ្រប់គ្រងដោយបុគ្គលជាជាងសាធារណជន ហើយឯកជនភាវូបនីយកម្មបែបនេះចង្អុលបង្ហាញអំពីវប្បធម៌ ឬរដ្ឋាភិបាលមួយដែលឱ្យតម្លៃលើវិស័យឯកជនជាងវិស័យសាធារណៈ នៅក្នុងការបង្កើតសេវាសង្គម។ ទីកន្លែងឯកជនបណ្តាលឱ្យមានការគ្រប់គ្រងតាមបែបមិនមែនប្រជាធិបតេយ្យលើការចូលឥរិយាបថ និងថ្លៃទីកន្លែងដែលអាចនាំឱ្យមានការរឹតត្បិតសិទ្ធិបន្ថែមទៀតពីជនក្រីក្រតាមរយៈការត្រួតពិនិត្យ

[5] Holmes, 2017. ‘Death of democracy in Cambodia as court dissolves opposition’. The Guardian.

[6] Garret, 2015. ‘The privatisation of cities’ public spaces is escalating’. The Guardian.

[7] Nemeth, 2012. p. 4.

ការចូលទៅកាន់ទីកន្លែងសម្រាប់ធ្វើ លំហាត់ប្រាណ សម្រាកលំហែសិក្សា និងការលេង។ បញ្ហាមិនមែនបណ្ដាលមកពីការមានទីកន្លែងឯកជនច្រើនពេកនោះទេ ប៉ុន្តែបណ្ដាលមកពីទីកន្លែង សាធារណៈនោះមានចំនួនតិចតួចពេកដែលអាចធ្វើឱ្យប្រជាពលរដ្ឋបាត់បង់អត្ថប្រយោជន៍ផ្សេងៗដែលទទួលបានពីទីកន្លែងនោះ។ ក្នុងអំឡុងពេលស្រាវជ្រាវ មានអ្នកឆ្លើយតបម្នាក់បានចោទសួរអំពីសារៈសំខាន់នៃទីកន្លែងសាធារណៈវិញថា "តើមានកន្លែងផ្សេង អាចឱ្យខ្ញុំធ្វើលំហាត់ប្រាណបានដែរឬទេ?"។ អ្នកឆ្លើយតបម្នាក់ទៀតគ្រាន់តែបានលើកឡើងថានាង "មានអារម្មណ៍សុវត្ថិភាព" ពេលនៅទីកន្លែងសាធារណៈ ដែលការលើកឡើងនេះគឺជាចំនុចមួយទៀតទៅក្នុងអត្ថប្រយោជន៍របស់ទីកន្លែងសាធារណៈអាចផ្ដល់ជូន ជាពិសេសនៅក្នុងបរិបទយែនឌ័រ និងអំពើហិង្សា។ ថ្វីត្បិតតែយ៉ាងនេះក៏ដោយ ការលក់ដីសាធារណៈរបស់រដ្ឋនៅទូទាំងផ្ទៃប្រទេសកម្ពុជា និងរាជធានីភ្នំពេញ នាពេលថ្មីៗនេះបានធ្វើឱ្យមានភាពចាំបាច់បង្កើតផែនទី និងធ្វើការស្រាវជ្រាវស្ដីពីទីកន្លែងសាធារណៈ។ ទីកន្លែងសាធារណៈងាយក្លាយទៅជាប្រយោជន៍ឯកជន ហើយសាធារណជនគួរយល់ដឹងឱ្យបានគ្រប់គ្រាន់អំពីហានិភ័យដែលទីកន្លែងនេះនឹងត្រូវប្រឈម។



*ទីកន្លែងសាធារណៈនៅខាងក្រៅបណ្ណាល័យជាតិជាមួយនឹងផ្ទាំងហាងកាហ្វេអាម៉ាហ្សូននៅពីក្រោយ (អង្គការសមាគមផាងត្នោត ឆ្នាំ២០១៨)*

អត្ថប្រយោជន៍នានានៃទីកន្លែងសាធារណៈ អាចមានការពិបាកក្នុងការវាស់វែង ប៉ុន្តែគេអាចដឹងថាវាមានអត្ថប្រយោជន៍ ចាប់តាំងពីការជួយសម្រួលដល់ការចូលរួមតាមបែបប្រជាធិបតេយ្យនៅក្នុងការជួយគ្រប់គ្រងផលប៉ះពាល់នៃអាកាសធាតុតាមរដូវកាល។ ទីកន្លែងសាធារណៈនៅប្រទេសចិន ដាណឺម៉ាកត្រូវបានគេប្រើប្រាស់ដើម្បីកាត់បន្ថយទឹកជំនន់ និងបានប្រែក្លាយទីកន្លែងទឹកជំនន់នោះ ទៅជាការរចនាដើម្បីបង្កើតជាទីកន្លែងកម្សាន្តប្រកបដោយសោភ័ណភាពថែមទៀតផង[8,9]។ ប៉ុន្តែនៅក្នុងទីក្រុងភ្នំពេញស្ទើរតែគ្មានទីកន្លែងសាធារណៈណាមួយត្រូវបានគិតគូអំពីករណីទឹកជំនន់ដែលទីក្រុងធ្លាប់ជួបប្រទះជាប្រចាំឡើយ។ ទីកន្លែងសាធារណៈអាចធ្វើឱ្យប្រជាពលរដ្ឋមានកម្មសិទ្ធិលើទីក្រុង ហើយពួកគេមានអារម្មណ៍ថាខ្លួនជាផ្នែកមួយនៃសង្គមដ៏ល្អមួយ។ ជាធម្មតា តាមទីកន្លែងសាធារណៈ មានដាក់តាំងរូបសំណាក ហើយប្រើប្រាស់ជាមធ្យោបាយដើម្បីកសាងនូវវប្បធម៌មួយ និងបង្ហាញនូវរូបភាព ឬស្នាដៃសិល្បៈគួរឱ្យកោតសរសើរ។

[8] Levitt and Myron, 2017. p.23,24.

[9] Perry, 2016. ‘Copenhagen’s public spaces that turn into picturesque ponds when it rains’. The Guardian.

រាជធានីភ្នំពេញ ទីកន្លែងសាធារណៈសម្បូរទៅដោយរូបសំណាកវីរៈបុរសប្រវត្តិសាស្ត្រខ្មែរដូចជា តេជោយ៉ត និងតេជោមាស ជាអ្នកចម្បាំងល្បីល្បាញក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលអង្គុយច្រកគាវលើខ្នងសេះនៅមាត់ទន្លេ។ រូបសំណាកលោក ជា វិជ្ជា ជាមេដឹកនាំសហជីពកម្មករល្បីឈ្មោះមួយរូប ដែលលោកឈរសន្ធឹងដងខ្លួនត្រង់ ហាក់ដូចជាគាត់កំពុងតែថ្លែងសុន្ទរកថានៅក្បែរកន្លែងដែលគាត់ត្រូវបានគេធ្វើឃាតក្នុងឆ្នាំ២០០៤។



*តេជោយ៉ត និងតេជោមាស នៅបណ្ដោយមាត់ទន្លេ (អង្គការសមាគមផាងត្នោត ឆ្នាំ២០១៨)*

ទីកន្លែងសាធារណៈក្នុងរាជធានីភ្នំពេញមានការរៀបចំឡើងខុសៗគ្នា ប៉ុន្តែជាទូទៅ វាជាកន្លែងបើកចំហ មានក្រាលបេតុងដើម្បីការពារពន្លឺថ្ងៃឬភ្លៀង។ ថ្វីត្បិតតែការដើរតាមបណ្ដោយមាត់ទន្លេមានខ្យល់បក់ត្រជាក់រំភើយ និងផ្ដល់ជូននូវទស្សនីយភាពទន្លេសាប ជាមួយនឹងកៅអី ដើមឈើ និងគ្រឿងបរិក្ខារហាត់ប្រាណបំពាក់នៅតាមផ្លូវក៏ដោយ ក៏ទីកន្លែងសាធារណៈទាំងនោះនៅតែមិនទាន់មានម្លប់គ្រប់គ្រាន់នៅពេលមានថ្ងៃក្ដៅ និងមេឃបើកថ្ងៃ ព្រមទាំងគ្មានអ្វីការពារទឹកភ្លៀងក្នុងរដូវវស្សាឡើយ។ ពាក់ព័ន្ធនឹងអាកាសធាតុក្នុងរាជធានីភ្នំពេញ ការរៀបចំទីកន្លែងសាធារណៈនានាហាក់ដូចជាមិនបានគិតគូរអំពីបរិស្ថានរូបវ័ន្ត និងវដ្ដអាកាសធាតុតាមរដូវរបស់ទីក្រុងនោះទេ។

គុណតម្លៃនៃកន្លែងទាំងនេះមិនមែនសុទ្ធតែ "ល្អ" ឬ "អាក្រក់" នោះឡើយ ហើយគុណតម្លៃនៃទីកន្លែងសាធារណៈនេះ គឺមិនមែនគ្រាន់តែបង្ហាញអំពីសមត្ថភាពផ្ដល់ជាម្លប់ បញ្ចៀសទឹកជំនន់ធ្វើឱ្យមានសោភ័ណភាពល្អ ឬអាចឱ្យប្រជាពលរដ្ឋសម្ដែងក្ដីបារម្ភរបស់ខ្លួនឡើយ។ ទោះបីជាលក្ខណៈវិនិច្ឆ័យទាំងនេះមានប្រយោជន៍យ៉ាងណាក៏ដោយ បញ្ហា "សាធារណៈ" នៃទីកន្លែងសាធារណៈសំដៅលើមធ្យោបាយដែលអាចបង្ហាញថាទីកន្លែងសាធារណៈមានសារៈសំខាន់ ដើម្បីទទួលបានទស្សនៈ និងការយល់ឃើញនានា របស់សាធារណជនដោយផ្ទាល់ ហើយ នេះគឺជាគោលបំណងនៃការសិក្សានេះធ្វើឡើងនៅទីតាំងមួយចំនួនក្នុងរាជធានីភ្នំពេញ។

ដោយហេតុថាទីកន្លែងសាធារណៈមិនទាន់មានការចងក្រងជាឯកសារ និងធ្វើផែនទីបង្ហាញទីតាំងនៅក្នុងរាជធានីភ្នំពេញ ដែលអាចចូលមើលបានដោយងាយស្រួល និងជាសាធារណៈ ដូច្នេះ ទីកន្លែងសាធារណៈទាំងនោះងាយរងគ្រោះដោយសារឯកជនភាវូបនីយកម្ម បទប្បញ្ញត្តិ ឬការចាត់ថ្នាក់ជាថ្មីដោយគ្មានការពិគ្រោះយោបល់ជាសាធារណៈ។ ឧទាហរណ៍ថ្មីៗនៃករណីនេះ គឺការចាត់ថ្នាក់ជាថ្មីទៅលើដីមាត់ទន្លេទំហំ ៩.២៥ ហិចតា ដែលផ្នែកមួយចំនួននៃដីនេះ គឺជាទីកន្លែងសាធារណៈ និងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលក្លាយជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ[10]។ ការចាត់ថ្នាក់ជាថ្មីនៃទីកន្លែងសាធារណៈ (ដីសាធារណៈរបស់រដ្ឋ) មកជាទីកន្លែងឯកជន (ដីឯកជនរបស់រដ្ឋ) អាចធ្វើឡើងដោយសារទីកន្លែងសាធារណៈ នោះបាត់បង់ការប្រើប្រាស់ប្រយោជន៍

[10] O'Byrne and Hor, 2018. 'Public lot on riverside eyed for major project'. The Phnom Penh Post.

សាធារណៈ។[11] អ្វីដែលជាធាតុផ្សំនៃពាក្យថា "ប្រើប្រាស់" នៅក្នុងបរិបទនេះមានភាពមិនច្បាស់លាស់នោះទេ ហើយដោយសារគ្មានការយល់ដឹង និងទស្សនៈយល់ឃើញរបស់អ្នករស់នៅក្នុងរាជធានីភ្នំពេញ ទីកន្លែងសាធារណៈអាចមើលឃើញថាជាដីទំនេរដែលអាចទិញ និងលក់ដោយគ្មានសារៈសំខាន់អ្វីភ្ជាប់ជាមួយសម្រាប់ប្រជាពលរដ្ឋកម្ពុជាឡើយ ម្យ៉ាងវិញទៀត លក្ខណៈវិនិច្ឆ័យសម្រាប់ការប្រើប្រាស់ប្រយោជន៍សាធារណៈ គឺមានការចូលរួមផុសផុលក្នុងការការពារទប់ទល់នឹងឯកជនភាវូបនីយកម្មទីកន្លែងសាធារណៈ ហើយលក្ខណៈវិនិច្ឆ័យនេះ នឹងត្រូវយល់កាន់តែច្បាស់នៅពេលយើងកំណត់និយមន័យថាតើអ្វីជាទីកន្លែងសាធារណៈ។



*ក្មេងប្រុសៗកំពុងលេងនៅពហុកីឡដ្ឋានជាតិអូឡាំពិក ដែលជាទីកន្លែងមួយក្នុងចំណោមទីកន្លែងសាធារណៈពេញនិយមបំផុតនៅក្នុងរាជធានីភ្នំពេញ (អង្គការសមាគមធាងត្នោត ឆ្នាំ២០១៨)*

## វិធីសាស្ត្រ

## ការកំណត់និយមន័យទីកន្លែងសាធារណៈ

ការសម្ភាសបុគ្គលសំខាន់ ការសិក្សាលើឯកសារដែលមាន និងការពិភាក្សាក្រុមជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ត្រូវបានប្រើប្រាស់នៅក្នុង របាយការណ៍នេះ ដើម្បីកំណត់និយមន័យនៃទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ។ ការសម្ភាសបុគ្គលសំខាន់ត្រូវបានធ្វើឡើងក្រោមទម្រង់ សម្ភាសពាក់កណ្តាលរៀបរយ ដើម្បីទទួលបានទស្សនៈស្តីពីទីកន្លែងសាធារណៈពីក្រុមសិទ្ធិមនុស្សក្នុងស្រុកដែលរួមមានអង្គការលីកាដូ (LICADHO) ក្រុមហ៊ុនអាជីវកម្មដែលពាក់ព័ន្ធនឹងការសាងសង់ទីកន្លែងសាធារណៈ ក្រុមហ៊ុនស្ថាបត្យកម្ម និងដេគ័រ អ៊ឹមអេអេ (MAA Architecture and Design) និងក្រុមហ៊ុន ស្ថាបត្យកម្ម និងដេគ័រ យូស៊ី (UC Design Build) ប៉ុន្តែសាលារាជធានីភ្នំពេញមិនបានឆ្លើយតបនឹងសំណើសុំជាផ្លូវការរបស់អង្គការសមាគមធាងត្នោតសម្រាប់ការសម្ភាសព័ត៌មានបន្ថែមឡើយ។ ការសិក្សាលើច្បាប់ភូមិបាលក៏ត្រូវបានធ្វើឡើង និងការប្រឹក្សាយោបល់ជាមួយអង្គការលីកាដូ ដើម្បីយល់ច្បាស់អំពីទស្សនៈផ្នែកច្បាប់ស្តីពីទីកន្លែងសាធារណៈផងដែរ។

---

[11] 2001 Cambodian Land Law, Article 16.

## និយមន័យផ្លូវច្បាប់

ដោយសារតែ "ទីកន្លែងសាធារណៈ" មិនត្រូវបានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុន្តែទីកន្លែងដែលគេស្គាល់យ៉ាងទូលំទូលាយថាជា "ទីកន្លែងសាធារណៈ" អាចត្រូវបានរៀបរាប់ជំនួសមកវិញនៅក្នុងផ្នែកដែលទាក់ទងនឹង "ទ្រព្យសម្បត្តិ ឬដីសាធារណៈរបស់រដ្ឋ" និង "ទ្រព្យសម្បត្តិ ឬដីសមូហភាព។" ទ្រព្យសម្បត្តិ ឬដីទាំងនេះត្រូវបានគេស្គាល់ថាជាការចាត់ថ្នាក់ដីតែពីរគត់ដែលផ្តល់ភាពមិនអាចទិញលក់បាន ដែលការធ្វើបែបនេះអាចធានាបានថាដីនេះជាកម្មសិទ្ធិរបស់សាធារណជន ឬរដ្ឋ។

យោងតាមមាត្រា ១៥[12] ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋគឺជាដីទាំងឡាយណា (ឬទ្រព្យសម្បត្តិ) ដែលមានលក្ខណៈណាមួយដូចតទៅ៖ ដីដើមកំណើតពីធម្មជាតិ ដូចជាបឹង ឬទន្លេ ដែលត្រូវបានអភិវឌ្ឍ ជាពិសេសសម្រាប់ការប្រើប្រាស់ទូទៅ ដូចជាអាកាសយានដ្ឋាន ឬផែ ដីដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ដូចជាផ្លូវ ឬឧទ្យានសាធារណៈ ដីដែលត្រូវបានផ្តល់ជូនដើម្បីបម្រើសេវាសាធារណៈ ដូចជាមន្ទីរពេទ្យ ឬសាលារៀន ដីដែលជាបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ ឬប្រវត្តិសាស្ត្រ ឬដែលជាអចលនទ្រព្យដែលមិនត្រូវបានកាន់កាប់ជាឯកជនដោយព្រះរាជវង្ស។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់បានឡើយ លើកលែងណាវាមិនត្រូវបានចាត់ថ្នាក់ជាថ្មី មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋសិន។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចចាត់ថ្នាក់ជាថ្មីមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន ប្រសិនបើទ្រព្យសម្បត្តិនោះបាត់បង់ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ[13]។ ដំណើរការវាយតម្លៃលើការប្រើប្រាស់ប្រយោជន៍សាធារណៈហាក់ដូចជាមិនបានបញ្ចូលការប្រឹក្សាយោបល់ជាមួយសាធារណជនទេ និងធ្វើឡើងដោយមន្ត្រី និងអ្នកជំនាញរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ[14]។

ទ្រព្យសម្បត្តិសមូហភាព មានដូចជា (ក) ទ្រព្យសម្បត្តិវត្ត ពោលគឺ ទ្រព្យសម្បត្តិទាំងឡាយណាដែលមាននៅក្នុងទីតាំងវត្តអារាម[15] ឬ (ខ) ទ្រព្យសម្បត្តិសហគមន៍ជនជាតិភាគតិច ពោលគឺ ដីដែលសហគមន៍ជនជាតិភាគតិចបានតាំងទីលំនៅ និងដែលពួកគេធ្វើកសិកម្មបែបប្រពៃណី[16]។ ទ្រព្យសម្បត្តិវត្តអារាមមិនអាចលក់បានឡើយ ប៉ុន្តែទ្រព្យសម្បត្តិសហគមន៍ជនជាតិភាគតិចអាចលក់ទៅឱ្យសមាជិកក្រុមបាន ប្រសិនបើពួកគេចង់ចាកចេញពីក្រុម ឬឈប់ធ្វើកសិកម្មតាមបែបប្រពៃណី។

## និយមន័យរបស់ប្រជាពលរដ្ឋកម្ពុជា

ទស្សនៈរបស់ប្រជាពលរដ្ឋកម្ពុជាស្តីពីទីកន្លែងសាធារណៈត្រូវបានបញ្ចូលទៅក្នុងនិយមន័យទីកន្លែងសាធារណៈដែលប្រើនៅក្នុងការសិក្សានេះ ដើម្បីធានាថាការងារយើងបង្ហាញយ៉ាងត្រឹមត្រូវថាតើប្រជាពលរដ្ឋកម្ពុជាមានទស្សនៈ និងការយល់ឃើញបែបណាចំពោះទីកន្លែងសាធារណៈនៅក្នុងស្ថានភាពជាក់ស្តែង។ ចំណុចរួមមួយដែលអ្នកចូលរួមក្នុងការពិភាក្សាបានមើលឃើញថា ក្រៅពីនិយមន័យផ្នែកច្បាប់អាចមានគោលគំនិតផ្សេងៗទៀតដែលអាចកំណត់ថាតើដីនោះជាកន្លែងសារធាណៈ ឬមិនមែន។

---

[12] 2001 Cambodian Land Law, Article 15.

[13] Ibid, Article 16.

[14] អនុក្រឹត្យស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ (លេខ១២៩អនក្រ/បក) - unofficially translated as: Sub-Decree on Provisions and Procedures of Converting the State Public. Properties and Public Legal Entities, 2006. No.129 ANRK/BK.

[15] Ibid, Article 21.

[16] Ibid, Article 26.

អ្នកចូលរួមជាច្រើនមិនដឹងថាដីប្រភេទណាត្រូវបានចាត់ថ្នាក់ស្របច្បាប់ជាដីរដ្ឋ ឬឯកជនទេ តែអាចរៀបរាប់ថាដីនោះត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច តែងតែប្រើប្រាស់យ៉ាងដូចម្តេច និងសន្មតថាប្រើប្រាស់យ៉ាងដូចម្តេច។ ម្យ៉ាងវិញទៀត អ្នកចូលរួមទាំងអស់បានយល់ស្របថាទីកន្លែងសាធារណៈគឺជាទីកន្លែងសាធារណៈ តែក្នុងករណីណាដែលសាធារណជនអាចប្រើប្រាស់បានប៉ុណ្ណោះ។ អ្នកចូលរួមខ្លះគិតថាទីកន្លែងសាធារណៈ គឺជាទីកន្លែងសាធារណៈតែក្នុងករណីណាដែលវាត្រូវបានបង្កើតឡើងសម្រាប់សាធារណជន។ ប៉ុន្តែគំនិតនេះមិនត្រូវបានយល់ស្របដោយអ្នកចូលរួមទាំងអស់នោះទេ។

អ្នកចូលរួមខ្លះបានរៀបរាប់អំពីមូលហេតុដែលទន្លេមិនត្រូវបានចាត់ទុកថាជាទីកន្លែងសាធារណៈ ដោយសារវាមិនត្រូវបាន "បង្កើតឡើង" សម្រាប់សាធារណជន។ អ្នកចូលរួមដទៃទៀតគិតថាសាលារៀន និងមន្ទីរពេទ្យគួរតែរាប់ចូលជាទីកន្លែងសាធារណៈ ប៉ុន្តែអ្នកខ្លះទៀតវិញមិនយល់ស្របនោះទេ ដោយលើកអំណះអំណាងថា អគាររដ្ឋាភិបាលមិនមែនជាទីកន្លែងសាធារណៈនោះទេ ដោយសារកន្លែងទាំងនោះមិនអាចឱ្យមនុស្សគ្រប់គ្នាមានសិទ្ធិចូលបាន។ ចំណុចសំខាន់នៃការអះអាងនេះគឺស្ថិតនៅត្រង់ថាតើវត្តអារាមអាចចាត់ទុកជាទីកន្លែងសាធារណៈដែរទេ។ អ្នកចូលរួមខ្លះបានអះអាងថា វត្តអារាមគឺជាកន្លែងសម្រាប់ប្រើប្រាស់ជាសាធារណៈដែលអនុញ្ញាតឱ្យមនុស្សគ្រប់គ្នាចូលបានដោយសេរី និងមានសារៈសំខាន់ជាប្រវត្តិសាស្ត្រនៅក្នុងសង្គមខ្មែរ និងជាកន្លែងជួបជុំផ្នែកវប្បធម៌ដ៏សំខាន់ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្សេងទៀតក៏បានធ្វើការកត់សម្គាល់ផងដែរថា ប្រជាពលរដ្ឋកម្ពុជាដែលកាន់សាសនាអ៊ីស្លាមមិនមានភាពងាយស្រួលក្នុងចូលទៅទីកន្លែងនោះទេ ទោះបីជាពួកគេត្រូវបានអនុញ្ញាតឱ្យចូលក៏ដោយ។ ក្នុងករណីនេះ ក៏មានការកត់សម្គាល់ក្នុងតំបន់វត្តភ្នំដែលតំបន់នេះត្រូវបានចាត់ទុកថាជាទីកន្លែងសាធារណៈ ដោយសារទីនេះគ្មានព្រះសង្ឃ ដូច្នេះត្រូវបានចាត់ទុកថាមានលក្ខណៈងាយស្រួលចំពោះអ្នកមិនកាន់ពុទ្ធសាសនា និងវត្តផ្សេងទៀតដែលមិនត្រូវបានចាត់ទុកជាទីកន្លែងសាធារណៈ ដោយសារអ្នកកាន់សាសនាអ៊ីស្លាម និងអ្នកមិនកាន់ពុទ្ធសាសនាអាចមានអារម្មណ៍ថាខ្លួនមិនអាចចូលក្នុងវត្តអារាមទាំងនោះបានដោយសារតែបញ្ហាសាសនារបស់ខ្លួន។

សម្រង់សម្តីសំខាន់ៗពីអ្នកចូលរួមក្នុងកិច្ចពិភាក្សាជាក្រុមរួមមាន៖

- "ទីកន្លែងសាធារណៈគួរតែអាចប្រើប្រាស់បានដោយសេរី និងមានទំហំធំទូលាយដែលអនុញ្ញាតឱ្យមនុស្សគ្រប់គ្នាអាចធ្វើលំហាត់ប្រាណ និងឱ្យសហគមន៍ទទួលបាននូវអត្ថប្រយោជន៍ផ្នែកសុខភាព។"
- "អាជ្ញាធរគួរតែផ្តល់ទីកន្លែងសាធារណៈឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋអាចជួបជុំគ្នា និងតស៊ូមតិលើបញ្ហារបស់ពួកគាត់។"
- "ប្រជាពលរដ្ឋចំណាយប្រាក់ដើម្បីទៅលេងនៅទីកន្លែងសាធារណៈ ដោយសារយើងមិនមានទីកន្លែងសាធារណៈនៅក្នុងសហគមន៍របស់យើង។ យើងទៅលេងនៅមាត់ទន្លេ ពហុកីឡដ្ឋានជាតិអូឡាំពិក ហើយវាមានចម្ងាយឆ្ងាយដែលត្រូវចំណាយប្រាក់ដើម្បីធ្វើដំណើរទៅកាន់ទីនោះ។ យើងអាចទៅបានត្រឹមតែម្តងក្នុង មួយខែប៉ុណ្ណោះ ព្រោះគ្មានទីកន្លែងសាធារណៈក្នុងសហគមន៍យើងឡើយ។"

- "ទីកន្លែងសាធារណៈត្រូវការសម្អាតបន្ថែម ដើម្បីឱ្យមានសោភ័ណភាពកាន់តែស្រស់ស្អាត។"
- "ទីកន្លែងសាធារណៈបម្រើផលប្រយោជន៍ដល់មនុស្សគ្រប់គ្នាដោយពុំចាំបាច់មានការអនុញ្ញាត ឬបង់ប្រាក់ឡើយ។ ទីកន្លែងសាធារណៈផ្តល់អត្ថប្រយោជន៍ដល់ជនក្រីក្រ យុវជន និងមនុស្សចាស់ និងអ្នកមានទ្រព្យសម្បត្តិផងដែរ។"
- "យើងប្រើប្រាស់ទីកន្លែងសាធារណៈនៅក្នុងបុរីក្បែរសហគមន៍។ យើងមិនមានទីកន្លែងសាធារណៈផ្ទាល់ខ្លួននោះទេ។"
- "ប្រសិនបើមានទីកន្លែងសាធារណៈបន្ថែមទៀតនៅក្នុងតំបន់ និងសហគមន៍ នោះប្រជាពលរដ្ឋនឹងទទួលបានអត្ថប្រយោជន៍ផ្សេងៗ ហើយប្រទេសជាតិក៏ទទួលបានអត្ថប្រយោជន៍ដូចគ្នាផងដែរ។"

## និយមន័យ "ទីកន្លែងសាធារណៈ"

និយមន័យនៃទីកន្លែងសាធារណៈខាងក្រោមនេះត្រូវបានប្រើប្រាស់ក្នុងរបាយការណ៍ តាំងពីដើមរហូតដល់ចប់ និងផ្អែកទៅលើការយល់ដឹងផ្នែកច្បាប់ និងវប្បធម៌ស្តីពីអ្វីដែលជាទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ឬមិនមែន។

### ទីកន្លែងសាធារណៈត្រូវតែៈ

១. មានលក្ខណៈមិនអាចទិញ ឬលក់ដូរបាន (មិនអាចលក់ យក ឬឱ្យ) ពោលគឺមានន័យថាទីកន្លែងសាធារណៈត្រូវស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ។

២. អាចឱ្យគ្រប់គ្នាប្រើប្រាស់បាន (ចូលដោយឥតគិតថ្លៃ គ្មានលក្ខខណ្ឌចូលដែលផ្អែកលើអាយុ ភេទ ពិការភាព ពូជសាសន៍ ឬសាសនានោះទេ។ បើកឱ្យប្រើប្រាស់បានដោយសេរី និងធ្វើសកម្មភាពផ្សេងៗបានតាមមធ្យោបាយជាច្រើន)។

៣. បង្កើតឡើង (មិនមែនដោយធម្មជាតិ) ក្នុងគោលបំណងទុកឱ្យសាធារណជនប្រើប្រាស់ជាប្រយោជន៍រួម។

ក. ភស្តុតាងដើម្បីវាយតម្លៃគោលបំណងបង្កើតទីកន្លែងសាធារណៈ មានដូចជាៈ

១. មានកៅអី សញ្ញាសម្គាល់ ម៉ាស៊ីនហាត់ប្រាណ ឬបរិក្ខារសម្រាប់ប្រើប្រាស់ជាសាធារណៈដទៃទៀត។

២. សេចក្តីប្រកាសជាផ្លូវការថាកន្លែងនោះទុកសម្រាប់ប្រើប្រាស់ជាសាធារណៈ។

៣. ការប្រើប្រាស់កន្លងមកបច្ចុប្បន្ន និងបន្តទៅអនាគតប្រើប្រាស់ដោយសាធារណជនពុំមានការរំខាន។

៤. ប្រើប្រាស់ជាប់លាប់ដោយឥតអាក់ខានដោយសាធារណជន។

៥. ទីកន្លែងរូបវន្តមួយ (របាយការណ៍នេះមិនបានធ្វើការស្រាវជ្រាវតាមអនឡាញ ឬទីកន្លែងសាធារណៈផ្សេងឡើយ។




*ដ្យាក្រាមវ៉ែនស្តីពីទីកន្លែងសាធារណៈ ជាមួយនឹងដ្យាក្រាមគំរូខាងក្រោម (អង្គការសមាគមផាងត្នោត ឆ្នាំ២០១៨)*

ដ្យាក្រាមវ៉េន (Venn Diagram) ខាងលើ បង្ហាញអំពីការភ្ជាប់អន្តរទំនាក់ទំនងយ៉ាងសំខាន់រវាងការយល់ដឹងផ្នែកច្បាប់ និងវប្បធម៌ទាក់ទងនៃទីកន្លែងសាធារណៈដែលការសិក្សានេះព្យាយាមស្វែងយល់ និងធ្វើការលើបញ្ហានេះ។ ម្យ៉ាងវិញទៀត ទីកន្លែងសាធារណៈមិនអាចចាត់ទុកជាដីសាធារណៈរបស់រដ្ឋដោយគ្រាន់តែវាមានព្រៃ ទន្លេ ការិយាល័យពន្ធ និងបញ្ជាការដ្ឋាននគរបាលនោះទេ ហើយលើសពីនេះ ទីកន្លែងសាធារណៈមិនអាចចាត់ទុកបានឡើយដោយគ្រាន់តែផ្អែកលើការយល់ដឹងផ្នែកវប្បធម៌របស់ប្រជាពលរដ្ឋបានទេ ដោយសារវាអាចងាយទទួលរងការទិញ និងការផ្ទេរសិទ្ធិបន្ទាប់ទៅទៀត។ គេឃើញថាទីកន្លែងសាធារណៈស្ថិតនៅរូបភាពទាំងពីរនេះ។ ក្រុមពិភាក្សាមិនទទួលបានការឯកភាពជាឯកច្ឆន្ទណាមួយទៅលើថាតើអគាររដ្ឋាភិបាល និងទីផ្សារគួរត្រូវចាត់ទុកជាទីកន្លែង សាធារណៈនៅឡើយទេ ហើយការធ្វើផែនទីទីកន្លែងទាំងនេះអាចនឹងពិបាកយល់ ពីព្រោះវាមានច្រើនកន្លែងពេក។ ចំណុចនេះមិនមែនមានន័យថា ទីផ្សារ សាលារៀន និងអគាររដ្ឋាភិបាលមិនដើរតួសំខាន់នៅក្នុងការប្រើប្រាស់ជាសាធារណៈនោះទេ ប៉ុន្តែវាគ្មានការឯកភាពជាឯកច្ឆន្ទថាទីកន្លែងទាំងនេះគួរត្រូវចាត់ទុកជាទីកន្លែងសាធារណៈ មូលហេតុចម្បងបំផុតគឺដោយសារការរឹតត្បិតទាក់ទងនឹងការចូលជាសាធារណៈទៅក្នុងទីកន្លែងទាំងនោះ។ ម្យ៉ាងវិញទៀតរបាយការណ៍ស្រាវជ្រាវស្ដីពីទីកន្លែងសាធារណៈនេះអាចចាត់ទុកថាផ្លូវគឺជាទីកន្លែងសាធារណៈ ប៉ុន្តែវាមិនមែនជាគោលដៅនៃការស្រាវជ្រាវនេះទេ ហើយអ្នកស្រាវជ្រាវមានបំណងធ្វើការលើប្រធានបទនេះនៅក្នុងរបាយការណ៍មួយផ្សេងទៀតស្ដីពីការទទួលបានជាសាធារណៈ។

## ការកំណត់ផែនទី

កាលណានិយមន័យ "ទីកន្លែងសាធារណៈ" ត្រូវបានកំណត់ឡើង អ្នកស្រាវជ្រាវចាប់ផ្ដើមរៀបចំធ្វើបញ្ជីទីកន្លែងសាធារណៈរបស់រាជធានី ដោយប្រើលក្ខណៈវិនិច្ឆ័យខាងលើ។ ដំណើរការនេះមានដូចជាការអង្កេតលើផ្លូវសំខាន់ៗនៃតំបន់ក្រៅរាជធានីភ្នំពេញសម្រាប់ទីកន្លែងសាធារណៈ តាមរយៈការសាកសួរប្រជាពលរដ្ឋមូលដ្ឋានថាតើពួកគេអាចចង្អុលប្រាប់អ្នកស្រាវជ្រាវពីទិសដៅទៅទីកន្លែងសាធារណៈបានដែរ ឬទេ និងប្រើប្រាស់ ផែនទីហ្គូហ្គល (Google Maps) ដើម្បីសាកល្បងស្វែងរក និងកំណត់ទីតាំងទីកន្លែងសាធារណៈផងដែរ។ ផ្លូវសំខាន់ៗចំនួនប្រាំពីរខ្សែត្រូវបានជិះឆ្លងកាត់ (ចាប់ពីដើមផ្លូវរហូតដល់ចុងផ្លូវនៅក្នុងព្រំប្រទល់រាជធានី) ហើយជាមធ្យមប្រជាពលរដ្ឋមូលដ្ឋាន ១០នាក់ ត្រូវបានសាកសួរនៅក្នុងតំបន់ក្រៅក្រុងនីមួយៗ។ ដំណើរការនេះធ្វើឡើងចាប់ពីថ្ងៃទី១ ខែមីនា រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨។

បន្ទាប់មកអ្នកស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោតបានធ្វើផែនទីកំណត់ទីតាំងទីកន្លែងសាធារណៈដែលត្រូវបានរកឃើញ ដោយការប្រើប្រាស់ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ (GPS) ឬកម្មវិធីម៉ាយម៉េផ ហ្គូហ្គល (My Maps Google) ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ជាច្រើនអាចបង្កើតផែនទីបានដោយប្រើកម្មវិធីកំណត់ផែនទីរបស់ ហ្គូហ្គល (Google) និងកម្មវិធីស្វែងរកទីតាំង។ កម្មវិធីនេះក៏ជាវិធីសាស្ត្រចម្បងមួយដែលប្រើសម្រាប់កំណត់ទីតាំងកន្លែងសាធារណៈតំបន់ក្នុងក្រុងផងដែរ ហើយការបញ្ជាក់អះអាងត្រូវបានធ្វើឡើងសម្រាប់ទីកន្លែងសាធារណៈនៅក្នុងតំបន់ទាំងនេះ បន្ទាប់ពីវាត្រូវបានកំណត់ផែនទី។

ក្រុមអ្នកស្រាវជ្រាវធ្វើការហៅទូរសព្ទទៅអាជ្ញាធរខាងក្រៅក្រុង ដូចជានាយករដ្ឋបាល បុគ្គលិកការិយាល័យខណ្ឌ និងអធិការនគរបាលដើម្បីបញ្ជាក់ទីតាំងភូមិសាស្ត្រដែលបានកំណត់រួចហើយ។ អាជ្ញាធរក្នុងខណ្ឌដង្កោ សែនសុខ មានជ័យ និងច្បារអំពៅ បានផ្តល់ការបំភ្លឺបន្ថែមអំពីទីកន្លែងសាធារណៈដែលខ្លួនបានដឹងនៅក្នុងតំបន់របស់ខ្លួន ខណៈដែលអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ និងព្រែកព្នៅមិនអាចទាក់ទងបានទេ។ អាជ្ញាធរខណ្ឌខាងក្នុងមិនអាចទាក់ទងបានខណៈដែលអ្នកស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោតអាចចូលទៅកាន់ទីកន្លែងសាធារណៈ និងសិក្សាស្រាវជ្រាវបានយ៉ាងងាយស្រួល។ លើសពីនេះទៅទៀត អ្នកស្រាវជ្រាវបានស្នើសុំឱ្យសាលារាជធានីភ្នំពេញផ្តល់ផែនទីទាំងឡាយណាដែលទាក់ទងនឹងទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ តែសាលារាជធានីភ្នំពេញគេបានបដិសេធ។

ផែនទីត្រូវបានផលិតឡើងដោយប្រើកម្មវិធី My Maps របស់ Google និងកម្មវិធីធ្វើផែនទី GIS ដើម្បីបង្ហាញទីតាំងទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ។ ជាងនេះទៅទៀត ការគណនាត្រូវបានធ្វើឡើងដោយប្រើកម្មវិធី My Maps ដើម្បីវាស់វែង និងគណនាក្រឡាផ្ទៃរបស់ទីកន្លែងសាធារណៈ។ ការងារនេះធ្វើឡើងសម្រាប់តែខណ្ឌក្នុងក្រុងតែប៉ុណ្ណោះ។ ចំពោះការរាប់ទីកន្លែងសាធារណៈ គឺអ្នកស្រាវជ្រាវពិនិត្យឡើងវិញទៅលើទីតាំងទាំងនោះម្តងមួយៗ និងកំណត់ថាតើទីកន្លែងទាំងនោះជាកន្លែងតែមួយ ឬច្រើន ដោយផ្អែកលើថាតើមានផ្លូវ ឬរបាំងខណ្ឌចែកទីកន្លែងនោះ ឬមានការផ្លាស់ប្តូរបរិយាកាស និងលក្ខណៈមួយចំនួនដែលសំខាន់អាចធានាថាវាត្រូវបានចាត់ទុកជាទីកន្លែងសាធារណៈ។ ឧទាហរណ៍សម្រាប់បញ្ហានេះគឺតំបន់មាត់ទន្លេដែលអាចចាត់ទុកជាទីកន្លែងសាធារណៈដ៏ធំមួយ ប៉ុន្តែត្រូវបានបែងចែកទៅជាទីកន្លែងសាធារណៈបីដោយ សារតំបន់ខាងជើង និងខាងត្បូងមានលក្ខណៈខុសគ្នា និងមានប្រជាប្រិយភាពទាបជាងតំបន់កណ្តាល។

## ទិន្នន័យចម្បង

ទិន្នន័យបឋមត្រូវបានប្រមូលដោយអ្នកស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោត ចាប់ពីថ្ងៃទី១ ខែមេសា រហូតដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។ក្នុងចន្លោះពីម៉ោង៧:០០ព្រឹក ដល់ ៨:០០ យប់ មនុស្ស៦០នាក់ ត្រូវបានសម្ភាសនៅតាមទីកន្លែងសាធារណៈល្បីជាងគេបំផុតចំនួន៦កន្លែង នៅតំបន់ក្នុងក្រុងភ្នំពេញ រួមមានពហុកីឡដ្ឋានជាតិអូឡាំពិក មាត់ទន្លេ សួនច្បារវត្តបុទុម មាត់ទន្លេកោះពេជ្រ[17] និងសួនច្បារសម្តេចហ៊ុនសែន។ គឺត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ហើយជាប្រជាពលរដ្ឋកម្ពុជា។ លើសពីនេះទៀត ដើម្បីធានាថាអ្នកស្រាវជ្រាវបានជួបក្រុមអ្នកប្រើប្រាស់ទីកន្លែងសាធារណៈបានច្រើន ពួកគេនឹងសម្ភាសតែម្នាក់ក្នុងចំណោមប្រជាពលរដ្ឋ៥នាក់ដែលពួកគេបានជួបដោយឥតគ្រោងទុកនៅពេលកំពុងដើរតាមទីកន្លែងសាធារណៈ។

## ដែនកំណត់

## ការចាត់ថ្នាក់

របាយការណ៍នេះពិចារណាទៅលើទីកន្លែងសាធារណៈដែលអាចមើលឃើញតែប៉ុណ្ណោះមានន័យថា អ៊ីនធឺណិត ឬបណ្តាញទំនាក់ទំនងផ្សេងទៀតមិនត្រូវបានរាប់បញ្ចូលឡើយ។ ជាងនេះទៅទៀត ទោះបីជា ទីកន្លែងសាធារណៈដែលខុសពីដីសាធារណៈត្រូវបានចាត់ថ្នាក់ដោយអាជ្ញា រដ្ឋបាលក៏ដោយក៏ទីនោះមិនត្រូវបានកត់ត្រាឡើយ ដោយសារមន្ត្រីនានា

[17] Diamond Island riverside was originally mapped as public space, but upon further research it was discovered that it does not meet the criteria to be considered public space (see page 13).

មិនមានបំណងចូលរួមក្នុងការសិក្សានេះទេ។ ដោយសារតែអង្គការសមាគមធាងត្នោតមិនអាចទទួលបានផែនទីដីធ្លីផ្លូវការនៃរាជធានីភ្នំពេញ យើងមិនអាចបញ្ជាក់អះអាងថាគ្រប់ទីកន្លែងសាធារណៈទាំងអស់ដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះប្រាកដជាស្ថិតនៅលើដីសាធារណៈរបស់រដ្ឋនោះឡើយ។



*ទីកន្លែងសាធារណៈនៅក្បែរវត្តភ្នំដែលមានហាងកាហ្វេស្ថិតនៅទីនោះ។ យើងមិនអាចកំណត់បានថាតើទីកន្លែងនោះត្រូវបានកាន់កាប់ជាកម្មសិទ្ធិ ឬជួលដោយម្ចាស់ហាងកាហ្វេ ឬយ៉ាងណានោះទេ ឬក៏ថាតើវាគ្រាន់តែត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មនៅទីនេះ ឬយ៉ាងនោះដែរ។ (អង្គការសមាគមធាងត្នោត ឆ្នាំ ២០១៨)*

### ចំនួន

វាពិតជាទំនង ថាទីកន្លែងសាធារណៈមួយចំនួនមិនត្រូវបានរាប់បញ្ចូលនៅក្នុងរបាយការណ៍នេះទេ ពីព្រោះយើងមិនអាចស្រាវជ្រាវក្នុងក្រុងទាំងមូលបាន ដោយសារពេលវេលាមិនគ្រប់គ្រាន់ ផែនទីមិនត្រូវបានផ្តល់ជូនដោយអាជ្ញាធរ ហើយការរាប់នេះទៀតសោតក៏ពិបាកផងដែរ ព្រោះទីកន្លែងសាធារណៈមួយចប់ក៏មានកន្លែងមួយទៀតចាប់ផ្តើម ហើយនេះគឺសុទ្ធតែគ្មានភាពច្បាស់លាស់ទាំងអស់។ ឧទាហរណ៍ ទិន្នន័យរបស់យើងគឺជាទិន្នន័យប្រមូលប្រញាប់ប្រញាល់មានកម្រិត និងមិនទាន់គ្រប់ជ្រុងជ្រោយនោះទេ។ លើសពីនេះទៀត ចំនួនទីកន្លែងសាធារណៈគ្រាន់តែជារង្វាស់មួយ ហើយវាត្រូវនឹងគុណភាព និងទំហំនៃទីកន្លែងទាំងនោះ។ ទីកន្លែងសាធារណៈចំនួន១០០កន្លែង អាចមានប្រយោជន៍តិចជាងទីកន្លែងសាធារណៈល្អ ១០កន្លែង ឬទីកន្លែងសាធារណៈ១០កន្លែងដែលគ្របដណ្តប់លើក្រឡាផ្ទៃធំជាងទីកន្លែងសាធារណៈ ១០០កន្លែង។ ឧទាហរណ៍ ពហុកីឡដ្ឋានអូឡាំពិកដែលត្រូវបានរាប់បញ្ចូលជាទីកន្លែងសាធារណៈមួយកន្លែងអាចបម្រើដល់ប្រជាពលរដ្ឋរាប់ពាន់នាក់ និងសកម្មភាពជាច្រើនក្នុងពេលដំណាលគ្នា។ គ្មានរង្វាស់ស្តង់ដារសម្រាប់ទីកន្លែងសាធារណៈដែលទីក្រុងមួយគួរតែមាននោះទេ ហើយចំនួនទាំងនេះមិនគួរត្រូវបានចាត់ទុកថាមានសារៈសំខាន់ស្មើនឹងគំនិតយោបល់របស់អ្នករស់នៅក្នុងរាជធានីភ្នំពេញ នៅពេលដែលពួកគេពិភាក្សាថា តើរាជធានីភ្នំពេញមានទីកន្លែងសាធារណៈដែលមានគុណភាពគ្រប់គ្រាន់ដែរ ឬទេ។

### ការគណនាក្រឡាផ្ទៃ

ដោយសារកម្មវិធី My Maps មិនអាចត្រឹមត្រូវ ១០០% ការវាស់វែងនៅក្នុងរបាយការណ៍នេះគឺជាតម្លៃប៉ាន់ស្មាន និងមិនអាចបកស្រាយថាត្រឹមត្រូវប្រាកដបានទេ។

ផែនទីទី១៖ ទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញ



ផែនទីទី២៖ ទីកន្លែងសាធារណៈនៃខណ្ឌខាងក្នុងរាជធានីភ្នំពេញ



ផែនទីទី៣៖ តំបន់នៃទីកន្លែងសាធារណៈនៃខណ្ឌខាងក្នុងរាជធានីភ្នំពេញ




| | | |
|---|---|---|
| ទីកន្លែងសាធារណៈនៃខណ្ឌខាងក្នុងរាជធានីភ្នំពេញ | ▬ ទីកន្លែងសាធារណៈ (ខណ្ឌខាងក្នុង) | ប្រភព៖ Google Maps ឆ្នាំ ២០១៨ |

## លទ្ធផលរកឃើញសំខាន់ៗ

### ក. ទីកន្លែងសាធារណៈ

តារាងទី១. ចំនួនទីកន្លែងសាធារណៈនៅក្នុងរាជធានីភ្នំពេញនៅខណ្ឌខាងក្នុង និងក្រៅ[18] ក្រឡាផ្ទៃសរុបនៃទីកន្លែងសាធារណៈនៅក្នុងខណ្ឌខាងក្នុង

| | |
|---|---|
| ខណ្ឌខាងក្នុង | ៦៦កន្លែង |
| ខណ្ឌខាងក្រៅ | ២១កន្លែង |
| ក្រឡាផ្ទៃសរុបនៃទីកន្លែងសាធារណៈរបស់ខណ្ឌខាងក្នុង | ៦៧,១៦៣ ហិចតា (៦៧,១៦៣០ម$^{២}$) [០.៦៧គ.ម$^{២}$] |

វាមានចំនួនទីកន្លែងសាធារណៈក្នុងខណ្ឌខាងក្នុង (៦៦) ច្រើនលើសបីដង នៃខណ្ឌខាងក្រៅ (២១)។ ហើយទីកន្លែងសាធារណៈទំហំប្រមាណ ០.៦៧គ.ម$^{២}$ នៅក្នុងខណ្ឌខាងក្នុងដែលភាគច្រើនស្ថិតនៅក្នុងខណ្ឌដូនពេញ ៧មករា និងចំការមន ក៏ប៉ុន្តែគ្មានទិន្នន័យប្រៀបធៀបសម្រាប់ខណ្ឌក្រៅក្រុងទេដោយសារពេលវេលាមានកម្រិតសម្រាប់អ្នកស្រាវជ្រាវ។ មានស្តង់ដារមួយចំនួនចំពោះទីកន្លែងសាធារណៈដែលទីក្រុងគួរតែមាន ហើយការសិក្សានេះផ្អែកលើគំនិតយោបល់របស់សាធារណជនថាតើមានទីកន្លែងសាធារណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៅក្នុងរាជធានីភ្នំពេញ ក៏ប៉ុន្តែទិន្នន័យបង្ហាញឱ្យឃើញនូវភាពមិនស្របគ្នារវាងខណ្ឌក្នុងក្រុង និងខណ្ឌក្រៅក្រុង។ ដើម្បីផ្តល់ជាគន្លឹះសម្រាប់គណនាក្រឡាផ្ទៃសរុបនៃទីកន្លែងសាធារណៈនៅខណ្ឌខាងក្នុងក្រុង (០.៦៧គ.ម$^{២}$) (ដូចមានរូបភាពនៅក្នុងផែនទីទី៤ ដែលមានក្រឡាផ្ទៃ ០.៦៧គ.ម$^{២}$ ដែលផាត់ពណ៌ពីលើ) មិនអាចស្មើនឹងទីកន្លែងសាធារណៈតែមួយនៅក្នុងកោះពេជ្រ។




| | | |
|---|---|---|
| ផែនទីទី៤. ទីកន្លែងសាធារណៈក្នុងខណ្ឌខាងក្នុងក្រុង | ▬ ទីកន្លែងសាធារណៈបូកបញ្ចូលគ្នា (ខណ្ឌខាងក្នុងក្រុង) | ប្រភព៖ Google Maps 2018 |

### ភាពខុសគ្នារវាងខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅក្រុង

និន្នាការមួយនៅក្នុងខណ្ឌខាងក្រៅក្រុងគឺដំបូងឡើយហាក់ដូចជាមាន "ទីកន្លែងសាធារណៈ" ច្រើន តែទីកន្លែងសាធារណៈសក្តានុពលស្ទើរតែ ៣០កន្លែងត្រូវបានលុបបំបាត់ បន្ទាប់ពីអ្នកស្រាវជ្រាវបានរកឃើញថាទីកន្លែងទាំងនោះស្ថិតនៅក្នុងបុរី ហើយដូច្នេះគឺវាស្ថិតនៅលើដីឯកជន។ យោងតាមរយៈការពិភាក្សាក្រុមនិងការសម្ភាសជាមួយសាធារណជន នៅពេលកំពុងប្រមូលទិន្នន័យសហគមន៍បិទជិតជាធម្មតាផ្តល់ទីកន្លែងសម្រាប់អ្នករស់នៅ ហើយក្នុងករណីខ្លះ វាអាចឱ្យសាធារណជនប្រើប្រាស់ទីកន្លែងទាំងនោះបាន។ ក៏ប៉ុន្តែ ទីកន្លែងទាំងនោះនៅតែអាចទិញលក់បាន ដោយផ្តល់សិទ្ធិឱ្យបុរីអាចហាមមិនឱ្យសាធារណជនប្រើប្រាស់ទីកន្លែង

[18] This table adds in additional public spaces that are not represented on the maps provided by authorities from Prek Pnov (1 space), Menchey (1 space), Chroy Changva (3 spaces), Chbar Ampov (2 spaces), Russey Keo (1 space).

សាធារណៈទាំងនោះព្រោះជាញឹកញាប់ ពួកគេធ្វើបែបនេះដោយប្រើក្រុមសន្តិសុខ និង របង ឬប៉ុស្តិ៍ត្រួតពិនិត្យនៅច្រកចូលទៅក្នុងបុរី។ បើទោះបីដូច្នេះក៏ដោយ បុរីទាំងនោះនៅតែមិនបានផ្តល់ជាទីកន្លែងសាធារណៈពិតប្រាកដមួយសម្រាប់សាធារណជននោះទេ។ ទីកន្លែងទាំងនោះស្របតាមលក្ខណៈវិនិច្ឆ័យជាទីកន្លែងសាធារណៈ តែមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ ដោយវាមិនស្ថិតនៅលើដីសាធារណៈរបស់រដ្ឋទេ។ ការវិភាគបន្ថែមលើទីកន្លែងទាំងនោះ បង្ហាញថាវាត្រូវបានកាន់កាប់ជាកម្មសិទ្ធិឯកជន ហើយការគ្រប់គ្រង ជារឿយៗត្រូវបានអនុវត្តន៍ហួសការប្រើប្រាស់របស់វាដោយអង្គភាពឯកជន។ ម្ចាស់ទីកន្លែងទាំងនោះមិនត្រឹមតែអាចគ្រប់គ្រងលើការចេញចូល និងសកម្មភាពផ្សេងៗប៉ុណ្ណោះទេ លើសពីនោះទៅទៀត ពួកគេថែមទាំងអាចគិតប្រាក់លើការចូលកន្លែងទាំងនោះ និងកម្ទេចទីកន្លែងសាធារណៈដែលមាននៅទីនោះចោលបានគ្រប់ពេលវេលាទៀតផង។

### ឯកជនតែប្រើប្រាស់ជាសាធារណៈ

កោះពេជ្រមានទីកន្លែងសាធារណៈសរុបចំនួន១២កន្លែង ដែលត្រូវបានលុបចេញពីការសិក្សានេះ។ យោងតាមប្រភពជាច្រើនបានឱ្យដឹងថា[19][20][21] កោះពេជ្រទាំងស្រើទាំងមូល ឥឡូវនេះកំពុងត្រូវបានអភិវឌ្ឍន៍ និងគ្រប់គ្រងដោយក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា (Overseas Cambodian Investment Company) ក្រោមកិច្ចសន្យាជួលរយៈពេលវែង ៩៩ ឆ្នាំ ផ្តល់ដោយសាលារាជធានីភ្នំពេញ។ នេះមាន ន័យថាដីជាកម្មសិទ្ធិឯកជន ដូច្នេះទីកន្លែងសាធារណៈទាំងឡាយដែលស្ថិតនៅទីនោះ គឺអាច "ទិញលក់បាន" ហើយវាមិនស្របតាមលក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់និងគូរផែនទីថាជាទីកន្លែងសាធារណៈស្របតាមនិយមន័យរបស់របាយការណ៍នេះទេ។

### ខ. ការប្រើប្រាស់ទីកន្លែងសាធារណៈ

ប្រជាពលរដ្ឋ៦០នាក់ដែលប្រើប្រាស់ទីកន្លែងសាធារណៈដែលត្រូវបានសម្ភាសក្នុងនោះមានបុរស ៣៣នាក់ និងស្ត្រី ២៧នាក់។ ប្រជាពលរដ្ឋភាគច្រើន (៦៥%) គឺជាយុវជន (អាយុចន្លោះពី ១៨ ទៅ ២៥ ឆ្នាំ)។ ក្រុមប្រជាពលរដ្ឋតិចជាងគេស្ថិតក្នុងចន្លោះអាយុ ៣៦ ទៅ ៤៥ឆ្នាំ ក្នុងនោះមានតែប្រជាពលរដ្ឋ៤នាក់ប៉ុណ្ណោះ ត្រូវបានសម្ភាស។

**តារាងទី ២៖ អាសយដ្ឋានរបស់អ្នកឆ្លើយតបការសម្ភាស**

| ល.រ | អាសយដ្ឋាន | ចំនួន | ភាគរយ |
|---|---|---|---|
| **ខណ្ឌខាងក្នុងរាជធានី** | | **៣៤** | **៥៧** |
| ១ | ចំការមន | ១២ | ២០ |
| ២ | ដូនពេញ | ៩ | ១៥ |
| ៣ | ៧ មករា | ៥ | ៨ |
| ៤ | ទួលគោក | ៤ | ៧ |
| ៥ | ឫស្សីកែវ | ៤ | ៧ |
| **ខណ្ឌខាងក្រៅរាជធានីឬ ខេត្ត** | | **២៦** | **៤៣** |
| ៦ | មានជ័យ | ៨ | ១៣ |
| ៧ | សែនសុខ | ៤ | ៧ |
| ៨ | ដង្កោ | ៤ | ៧ |
| ៩ | ជ្រោយចង្វារ | ៣ | ៥ |
| ១០ | ច្បារអំពៅ | ៣ | ៥ |
| ១១ | ពោធិ៍សែនជ័យ | ២ | ៣ |
| ១២ | កណ្តាល | ២ | ៣[22] |
| ១៣ | ព្រែកព្នៅ | ០ | ០ |
| **សរុប** | | **៦០** | **១០០** |

[19] http://www.ocic.com.kh/en/elite-town.html. Accessed on the 18.5.2018.

[20] Rith, 2006. 'Koh Pich holdouts yield to city landing force.' The Phnom Penh Post.

[21] Peou, 2014. 'Chroy Changvar Satellite City Construction Project Is In Progress'. Agence Kampuchea Presse.

[22] Kandal province is outside the perimeters of the city and was included in the outer khans for the purposes of separating respondents based on proximity to the city centre.

ខណៈដែលអ្នកឆ្លើយតបសម្ភាសភាគច្រើនមកពីខណ្ឌខាងក្នុងក្រុង (៥៧%) អ្នកឆ្លើយតបសម្ភាស ៤៣% មានមកពីខណ្ឌខាងក្រៅក្រុង និងខេត្ត ដែលបង្ហាញថាទីកន្លែងសាធារណៈក្នុងខណ្ឌខាងក្នុងក្រុង មានប្រជាប្រិយភាពចំពោះអ្នករស់នៅក្នុងខណ្ឌខាងក្រៅក្រុង។ ដូចអ្វីដែលបានរំពឹងទុកការចូលទីកន្លែងសាធារណៈដោយការដើរមានភាគរយអ្នករស់នៅក្នុងខណ្ឌខាងក្នុងក្រុង (១៧.៦%) ខ្ពស់ជាងអ្នករស់នៅក្នុងខណ្ឌខាងក្រៅក្រុង (0%)។ អ្នកប្រើប្រាស់ទីកន្លែងសាធារណៈភាគច្រើនចូលទៅកាន់ទីកន្លែងទាំងនោះដោយជិះម៉ូតូ ខណៈដែលគ្មានអ្នកប្រើប្រាស់ណាម្នាក់ បានប្រើមធ្យោបាយធ្វើដំណើរសាធារណៈដើម្បីចូលទីនោះឡើយ ដែលនេះបង្ហាញឱ្យឃើញថា មធ្យោបាយធ្វើដំណើរសាធារណៈមិនទាន់ផ្តល់តម្រូវការធ្វើដំណើរទៅកាន់ទីកន្លែងសាធារណៈបានគ្រប់គ្រាន់សម្រាប់អ្នករស់នៅក្នុងខណ្ឌខាងក្រៅក្រុងនៅឡើយ។

**គ. ការយល់ឃើញទាក់ទងនឹងទីកន្លែងសាធារណៈ**

អ្នកឆ្លើយតបសម្ភាស ៩៨% បានគិតថាទីកន្លែងសាធារណៈមានសារៈសំខាន់។

**អត្ថប្រយោជន៍របស់ទីកន្លែងសាធារណៈ**

អ្នកចូលរួមភាគច្រើនគិតថាលក្ខណៈសំខាន់នៃទីកន្លែងសាធារណៈរួមមាន កន្លែងសម្រាប់ហាត់ប្រាណ (៩0%) សម្រាកលំហែ (៨0%) និងការកម្សាន្ត (៧៨%)។ អត្ថប្រយោជន៍ដទៃទៀតនៃទីកន្លែងសាធារណៈដែលអ្នកឆ្លើយតបសម្ភាសបានរៀបរាប់រួមមាន ការលក់ដូរតាមដងផ្លូវ (១៥%) ការធ្វើអាជីវកម្មខ្នាតតូច (១១%) ការកសាងទំនាក់ទំនង (៨%) និងការចូលរួមរបស់ប្រជាពលរដ្ឋ (១១%)។ ការសង្កត់ធ្ងន់ទៅលើការហាត់ប្រាណ ការលេងកម្សាន្ត និងការសម្រាកលំហែ ថាជាលក្ខណៈសំខាន់របស់ទីកន្លែង សាធារណៈជាសញ្ញាបញ្ជាក់ពីការព្រួយបារម្ភអំពីសុខមាលភាពផ្លូវកាយ ក៏ដូចជា ការចង់រីករាយក្នុងទីក្រុង។

**ការប្រើប្រាស់ទីកន្លែងសាធារណៈនាពេលបច្ចុប្បន្ន**

ការប្រើប្រាស់ទីកន្លែងសាធារណៈនាពេលបច្ចុប្បន្នបង្ហាញថាការសម្រាកលំហែ (៧0%) ការហាត់ប្រាណ (៥0%) និងការលេងកម្សាន្ត (៤៣%) គឺជាការប្រើប្រាស់ចម្បងនៃទីកន្លែងសាធារណៈ ដែលជាចម្លើយអាទិភាពរបស់អ្នកឆ្លើយតបសម្ភាស នៅពេលពិភាក្សាកអំពីលក្ខណៈសំខាន់ៗរបស់ទីកន្លែងសាធារណៈ។ កន្លែងសម្រាប់ជួបជុំគ្នា (២៥%) និងញ៉ាំអាហារតាមផ្លូវ (១១%) ក៏ជាការប្រើប្រាស់គួរឱ្យកត់សម្គាល់ផងដែរ។ ទោះបីជាយ៉ាងនេះក្តី កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានហាមអ្នកលក់តាមដងផ្លូវមិនឱ្យលក់នៅទីកន្លែងសាធារណៈមួយក្នុងចំណោមទីកន្លែងសាធារណៈពេញនិយមបំផុតរបស់រាជធានី គឺសួនច្បារមុខវត្តបុទមវត្តី[23]។ ការលក់អាហារតាមដងផ្លូវដែលមិនត្រឹមតែសំខាន់សម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏សំខាន់សម្រាប់ការបង្កើតសកម្មភាពនេះ

[23]Taing and Marrazzi Sassoon, 2018. 'Unhappy Hour: Bars, other vendors cleared from Phnom Penh's Wat Botum Park'. The Phnom Penh Post.

នៅតាមទីកន្លែងសាធារណៈ មិនគួរត្រូវបានមើលរំលងឡើយ។ អ្នកឆ្លើយតបសម្ភាស ១១% ឆ្លើយថាពួកគេទៅទីកន្លែងសាធារណៈដើម្បីញ៉ាំអាហារតាមដងផ្លូវ ហើយសេចក្តីសម្រេចដែលធ្វើឡើងដោយអាជ្ញាធរទាក់ទងនឹងទីកន្លែងសាធារណៈ នៅក្នុងក្រុងគួរពិចារណាអំពីសារៈសំខាន់នៃអាហារតាមដងផ្លូវសម្រាប់សាធារណជន។ ទីកន្លែងសាធារណៈដែលលក់អាហារតាមដងផ្លូវគួរត្រូវសិក្សាបន្ថែម ពីព្រោះសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតែជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋជាច្រើន។ ឧទាហរណ៍ នៃទីកន្លែងសាធារណៈតាមទ្រឹស្តីដែលអាចផ្តោតលើអាហារតាមដងផ្លូវ រួមមានដីចំណតដែលត្រូវបានកែប្រែទៅជាតូបអាហារតាមដងផ្លូវ និងទីកន្លែង សាធារណៈដែលអនុញ្ញាតឱ្យលក់នៅក្នុងម៉ោងជាក់លាក់ណាមួយ។

ពាក់កណ្តាលនៃអ្នកឆ្លើយតបបាននិយាយថាការហាត់ប្រាណគឺជាការប្រើប្រាស់សំខាន់មួយនៃទីកន្លែងសាធារណៈ ហើយរាជរដ្ឋាភិបាលគួរទទួលបាននូវការកោតសរសើរដែលបានផ្តល់កន្លែងសម្រាប់ហាត់ប្រាណដល់ប្រជាពលរដ្ឋ។ កន្លែងទាំងនេះគួរត្រូវកែលម្អបន្ថែមទៀត ដើម្បីទទួលបានប្រជាប្រិយភាព និងអត្ថប្រយោជន៍សុខភាព ក៏គួរតែបង្កើតឱ្យមាននៅខណ្ឌខាងក្រៅក្រុងផងដែរ ព្រោះមានទីកន្លែងសាធារណៈតិចជាង ៥ ដែលមានបំពាក់គ្រឿងបរិក្ខារហាត់ប្រាណ។



*កន្លែងហាត់ប្រាណមួយនៅតាមបណ្តោយមាត់ទន្លេ។ កន្លែងទាំងនេះមានម៉ាស៊ីនហាត់ប្រាណជាសារធារណៈ ដែលអាចប្រើបានដោយឥតគិតថ្លៃ។ ទីកន្លែងសាធារណៈដទៃទៀតផ្តល់ជូនជាទីកន្លែងសម្រាប់លេងកីឡា ដើរ រត់ ឬរាំ និងរៀនយោហ្គា។ (អង្គការសមាគមធាងត្នោត ឆ្នាំ២០១៨)*

## តួលេខទី១៖ លក្ខណៈនៃទីកន្លែងសាធារណៈល្អ



អ្នកឆ្លើយតបសម្ភាសយល់ថា លក្ខណៈសំខាន់នៃទីកន្លែងសាធារណៈដែល "ល្អ" គឺរួមមានដើមឈើកូនរុក្ខជាតិ (៨៦.៦%) ធុងសំរាម (៨០%) កៅអី និងកន្លែងសម្រាកលំហែ (៥៨.៣%) សារអប់រំ (៥៦.៦%) កន្លែងហាត់ប្រាណ (៤៨.៣%) និងមានទឹកស្អាត (៤៣.៣%)[24]។ កន្លែងធ្វើបាតុកម្ម (៦.៦%) និងកន្លែងរកលុយ (១០%) មិនត្រូវបានអ្នកចូលរួមវាយតម្លៃខ្ពស់ថា ជាលក្ខណៈនៃទីកន្លែងសាធារណៈល្អទេ។ អ្នកស្រាវជ្រាវបានសង្កេតឃើញថា ម្លប់គឺជាផ្នែកមួយមិនអាចខ្វះបាននៃទីកន្លែងសាធារណៈនៅពេលថ្ងៃ និង និងពេលរាត្រីមានភាគរយខ្ពស់ជាងអ្នកប្រើប្រាស់នៅពេលថ្ងៃ។ នេះអាចពាក់ព័ន្ធនឹងមូលហេតុសំខាន់ ២ គឺ៖ (១) អ្នកប្រើប្រាស់ទីកន្លែងសាធារណៈទាំងនោះ ជាញឹកញាប់មានការងារពេញម៉ោង និងមិនអាចប្រើប្រាស់ទីកន្លែងសាធារណៈនៅក្នុងម៉ោងធ្វើការ (ជាធម្មតា ចាប់ពីម៉ោង ៨:00 ព្រឹក ដល់ ម៉ោង ៥:00 ល្ងាច) និង (២) អ្នកប្រើប្រាស់ទីកន្លែងសាធារណៈទាំងនោះមិនចង់ប្រើប្រាស់ទីកន្លែងសាធារណៈនៅពេលមេឃក្តៅខ្លាំងនៅពេលថ្ងៃ។ គួរបញ្ជាក់ថា អ្នកស្រាវជ្រាវបានរំពឹងថា ម្លប់នឹងដើរតួនាទីដ៏សំខាន់ដល់ទីកន្លែងសាធារណៈមានលក្ខណៈល្អ តែវាត្រូវបានលើកឡើងដោយច្បាស់លាស់ម្តងណាឡើយ។ ការពិតគឺថាដើមឈើ ឬកូនរុក្ខជាតិជាការឆ្លើយតបមានកម្រិតខ្ពស់ អាចបង្ហាញថាអ្នកឆ្លើយតបសម្ភាសយល់ថាការប្រើប្រាស់ដើមឈើដើម្បីបង្កើតជាម្លប់គឺជាកត្តាសំខាន់សម្រាប់ទីកន្លែងសាធារណៈល្អ បើទោះបីជាចំណុចនេះ មិនដែលត្រូវបានលើកឡើងសោះ និងត្រឹមតែជាការសន្និដ្ឋាន។ រូបខាងក្រោមបង្ហាញឧទាហរណ៍មួយ ស្តីពីអ្វីដែលអ្នកស្រាវជ្រាវបានរកឃើញថា មានលក្ខណៈពិតៗនៃទីកន្លែង សាធារណៈជាច្រើននៅក្នុងខណ្ឌខាងក្នុងក្រុង ពោលគឺ ការប្រើប្រាស់ទាក់ទងនឹងពន្លឺថ្ងៃ និងពេលវេលា។ គួរបញ្ជាក់ថាទីកន្លែងសាធារណៈតាមមាត់ទន្លេមានដាំដើមដូងដែលមិនផ្តល់ម្លប់បានដូចពូជដើមឈើផ្សេងទៀតទេ។



*ទិដ្ឋភាពតាមបណ្តោយមាត់ទន្លេនៅពេលថ្ងៃ (រូបខាងលើ) និងពេលរាត្រី (រូបខាងក្រោម) (អង្គការសមាគមធាងត្នោត ឆ្នាំ២០១៨)*

**ទីកន្លែងសាធារណៈល្អបំផុត**

នៅពេលសុំឱ្យរៀបរាប់ទីកន្លែងសាធារណៈមួយណាជាទីកន្លែងសាធារណៈល្អបំផុតនៅក្នុងរាជធានីភ្នំពេញ ចម្លើយពេញនិយមជាងគេបំផុត គឺសួនវត្តបុទុម (៣១%) បន្ទាប់មក គឺសួនច្បារមុខព្រះបរមរាជវាំង និងតំបន់មាត់ទន្លេទល់មុខព្រះបរមរាជវាំង (១៧.៨%) និងពហុកីឡដ្ឋានអូឡាំពិក (១៥%)។

[24] (%) denotes the percentage of respondents that gave this answer.

## ឃ. បញ្ហានៅទីកន្លែងសាធារណៈ

អ្នកឆ្លើយតបសម្ភាសមួយចំនួន (១០%) មានអារម្មណ៍ថា ខ្លួនត្រូវបានផាត់ចេញពីទីកន្លែងសាធារណៈ។ របាយការណ៍មិនបានសិក្សាពីមូលហេតុនៅពីក្រោយបញ្ហាទាំងនេះទេ ហើយបញ្ហានេះគួរត្រូវសិក្សាលម្អិតនាពេលអនាគត។ មានការព្រួយបារម្ភថា ប្រជាពលរដ្ឋដែលគ្មានទីជម្រកកំពុងត្រូវបានផាត់ចេញពីទីកន្លែងសាធារណៈមួយចំនួន ដោយក្នុងនោះ អ្នកខ្លះត្រូវបានវាយដំពីសំណាក់មន្ត្រីនគរបាលដោយចោទពួកគេថាបង្កភាពរញ៉េរញ៉ៃនៅទីកន្លែងនោះ (Springer ២០១៥) ហើយអ្នករកស៊ីផ្លូវភេទ និងអ្នកលក់តាមដងផ្លូវ ក៏ត្រូវបានរឹតត្បិតក្នុងការចូលទីកន្លែងសាធារណៈផងដែរ[25]។ នេះគឺក្តីបារម្ភចម្បងមួយដែលត្រូវដោះស្រាយនិងសិក្សាបន្ថែមប្រសិនបើទីកន្លែងសាធារណៈនៅតែមិនអាចចូលបានដោយសេរីទៀត។

**តួលេខទី២៖ បញ្ហានៅទីកន្លែងសាធារណៈ**




បញ្ហាផ្សេងទៀត នៅទីកន្លែងសាធារណៈត្រូវបានបង្ហាញនៅក្នុងរូបទី២។ គួរកត់សម្គាល់ថា សំរាម (៤០%) និងភាពកខ្វក់ (៤៣%) គឺជាបញ្ហាដែលអ្នកឆ្លើយតបសម្ភាសជាច្រើននាក់បានលើកឡើង។ អ្នកឆ្លើយតបសម្ភាស (១២%) បានលើកឡើងថាការខ្លាចបាត់បង់ទីកន្លែងសាធារណៈ ឬទីកន្លែងសាធារណៈដែលបានបាត់បង់ គឺជាបញ្ហាមួយផងដែរ។ បញ្ហានេះត្រូវលើកយកមកពិចារណាស្របតាមច្បាប់ភូមិបាលនៅពេលមានសេចក្តីសម្រេចនានាត្រូវបានធ្វើឡើងទាក់ទងនឹងការចាត់ថ្នាក់ពីដីសាធារណៈរបស់រដ្ឋមកមកជាដីឯកជនរបស់រដ្ឋ ដែលអាចធ្វើឡើងក្នុងករណីដីបាត់បង់ "ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ"។ អ្នកឆ្លើយតបសម្ភាស ៨៨% បាននិយាយថារាជធានីភ្នំពេញត្រូវការទីកន្លែងសាធារណៈបន្ថែមទៀត។ នៅពេលសួរថាតើរាជធានីភ្នំពេញត្រូវការទីកន្លែងសាធារណៈប្រភេទណា អ្នកឆ្លើយតបសម្ភាស ៥៨% និយាយថា សួន បឹង ឬតំបន់ធម្មជាតិបន្ថែមទៀតដោយតំបន់កម្សាន្ត (៤៨%) និងកន្លែងសម្រាប់ហាត់ប្រាណ (៤៦%) ជាជម្រើសទីពីរ និងទីបី ដែលត្រូវការច្រើនបំផុត។ គួរឱ្យចាប់អារម្មណ៍ថា ពាក់កណ្តាលនៃចំនួនអ្នកសម្ភាសនិយាយថាពួកគេប្រើប្រាស់ទីកន្លែងសាធារណៈដើម្បីហាត់ប្រាណ ហើយក៏ចង់បានទីហាត់ប្រាណទេ។ លើសពីនេះទៅទៀត ការដែលអ្នកឆ្លើយតបសម្ភាស ៥៨% ចង់បានទីកន្លែងសាធារណៈបន្ថែមដែលរួមបញ្ចូលធម្មជាតិ អាចបង្ហាញឱ្យឃើញថាទីកន្លែងសាធារណៈបរាជ័យក្នុងការបញ្ចូលដើមឈើ និងទឹកបានសមស្របទេ ព្រោះថាវាមិនមានទីកន្លែងគ្រប់គ្រាន់ដែលអាចនឹងបាត់ឱកាសសម្រាប់រាជធានីភ្នំពេញ ដោយពិចារណាលើការប្រើប្រាស់ទីកន្លែងសាធារណៈដើម្បីកាត់បន្ថយផលប៉ះពាល់នៃទឹកជំនន់ដែលត្រូវបានអនុវត្តដោយជោគជ័យនៅក្នុងប្រទេសចិន និងដាណឺម៉ាក[26]។

[25] Taing and Marazzi Sassoon, 2018. 'Unhappy Hour: Bars, other vendors cleared from Phnom Penh's Wat Botum Park'. The Phnom Penh Post.

[26] Ibid footnote 2 and 3.

## តួលេខទី៣៖ ទីកន្លែងសាធារណៈបន្ថែមទៀត




## ង. ការបង្កើតទីកន្លែងសាធារណៈ

អ្នកឆ្លើយតបសម្ភាស ៩០% បាននិយាយថាពួកគេជឿជាក់ថាការបង្កើតទីកន្លែងសាធារណៈគឺជាតួនាទីរបស់រាជរដ្ឋាភិបាល។ លទ្ធផលហាក់ដូចជាបង្ហាញថា ការបង្កើតទីកន្លែងសាធារណៈនៅតាមបុរីមិនត្រូវបានចាត់ទុកជា ផែនការសមរម្យសម្រាប់អនាគតនៃទីកន្លែងសាធារណៈឡើយ។ ជាការពិត អ្នកឆ្លើយតបសម្ភាសស្ទើរតែទាំងអស់គិតថា ត្រូវការទីកន្លែងសាធារណៈបន្ថែមនៅក្នុងទីក្រុង ហើយរាជរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវលើការបង្កើតទីកន្លែងសាធារណៈដែលទំនងជាបង្ហាញថានេះគឺជាអាទិភាពមួយសម្រាប់ផែនការដើរឆ្ពោះទៅមុខទៀតរបស់អាជ្ញាធរ។

## ករណីសិក្សាទី១៖ ទីលានប្រជាធិបតេយ្យត្រូវបានផ្លាស់ប្ដូរកន្លែងថ្មី

ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលបានអនុម័តក្នុងឆ្នាំ២០០៩ តម្រូវឱ្យរាជធានី និងខេត្តទាំងអស់បង្កើតតំបន់មួយសម្រាប់ការប្រមូលផ្ដុំជាសាធារណៈ ដើម្បីធានាឱ្យបាននូវសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរតាមរយៈការប្រមូលផ្ដុំដោយសន្តិវិធី[27]។ ទីលានប្រជាធិបតេយ្យរាជធានីភ្នំពេញដែលបានបង្កើតនៅក្នុងខណ្ឌដូនពេញ ក្បែរវត្តភ្នំ គឺជាទីកន្លែងមួយរបស់រាជធានីភ្នំពេញ និងមានក្រឡាផ្ទៃ១.២ហិចតាស្ថិតនៅកណ្ដាលរាជធានីភ្នំពេញ[28]។ ដោយបានរៀបចំពីដំបូងឡើយដោយរាជរដ្ឋាភិបាលកាលពីខែវិច្ឆិកា ឆ្នាំ២០១០ទីលាននេះគឺជាតំបន់អនុញ្ញាតតែមួយគត់របស់ទីក្រុងសម្រាប់ធ្វើការតវ៉ាទាមទារផ្សេងៗ។ ការប្ដេជ្ញាចិត្តចំពោះលទ្ធិប្រជាធិបតេយ្យបែបចូលរួមដែលរាជរដ្ឋាភិបាលបានអនុញ្ញាតតាមរយៈការបង្កើតទីកន្លែងសម្រាប់ការតវ៉ាក្នុងលក្ខខណ្ឌ ដែលអ្នកតវ៉ាបានបំពេញទម្រង់បែបបទតាមផ្លូវច្បាប់រួចរាល់ អាចមើលឃើញថាជាសកម្មភាពវិជ្ជមានមួយនៅក្នុងការផ្ដល់ជូនប្រជាពលរដ្ឋនូវសិទ្ធិទទួលបានសេរីភាពបញ្ចេញមតិ និងការធ្វើបាតុកម្មដោយសន្តិវិធី។

ទោះបីជាយ៉ាងណាក៏ដោយ ទីលានប្រជាធិបតេយ្យត្រូវបានបិទមិនឱ្យមានការតវ៉ាតាំងពីថ្ងៃទី ៤ ខែមករា ឆ្នាំ២០១៤ មកម្ល៉េះ បន្ទាប់ពីអាជ្ញាធរបានចុះរុះរើវេទិការតវ៉ារបស់គណបក្សប្រឆាំងនៅទីនោះ។ ក្រោយមក សាលារាជធានីបានសាងសង់ទីលានធិបតេយ្យថ្មីមួយនៅតាមបណ្ដោយដងទន្លេសាប ស្ថិតនៅចម្ងាយប្រហែលប្រាំគីឡូម៉ែត្រពីទីតាំងចាស់។ ទីលានប្រជាធិបតេយ្យថ្មីមិនស្ថិតនៅចំកណ្ដាលរាជធានីទេ និងត្រូវបានដាក់ឱ្យនៅជាយក្រុង ស្របគ្នាជាមួយនឹងការបង្ក្រាបថ្មីៗលើបទដ្ឋានប្រជាធិបតេយ្យ ដូចជា ការបិទសារព័ត៌មាន និងការរំលាយគណបក្សប្រឆាំងធំបំផុតដែលធ្វើឱ្យប្រទេសកម្ពុជាបានចាកឆ្ងាយពីបទដ្ឋានប្រជាធិបតេយ្យនៅប៉ុន្មានឆ្នាំងចុងក្រោយនេះ។ ទោះបីជាទីលានថ្មីមានទំហំធំជាងទីលានមុនក៏ដោយ ប្រជាពលរដ្ឋជាច្រើនបាននិយាយថាពួកគេនឹងមិនតវ៉ានៅទីនោះទេ ពីព្រោះវាស្ថិតនៅឆ្ងាយពីទីក្រុង[29]។



*អតីតទីលានប្រជាធិបតេយ្យ (សារព័ត៌មានអេប៊ីស៊ី-ABC News ឆ្នាំ២០១៣)*

---

[27] Law on Peaceful Demonstration, 2009.

[28] Sokheng, 2010. ‘Freedom park inaugurated’. The Phnom Penh Post.

[29] Sun, 2017. ‘As gov’t prepares to shutter freedom park for good residents express mixed views on its legacy’. VOA Cambodia.

## ករណីសិក្សាទី២៖ ពីសាធារណៈមកជាឯកជន

ដីមាត់ទន្លេទំហំ ៩២,៥៣៨ ម៉ែត្រក្រឡា ចាប់ពីផ្សាររាត្រីរហូតដល់ស្ពានជ្រោយចង្វារ ភាគខាងកើតនៃវិថីស៊ីសុវត្ថិ រួមទាំងកំពង់ផែស្វយ័តភ្នំពេញ ត្រូវបានចាត់ថ្នាក់ជាថ្មីពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ នៅក្នុងអនុក្រឹត្យមួយដែលចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែមីនា ឆ្នាំ២០១៨។ នេះបង្ហាញ ថាទីកន្លែងសាធារណៈងាយនឹងក្លាយទៅជារបស់ឯកជន។ ដីនេះត្រូវបានប៉ាន់ប្រមាណថាមានតម្លៃចន្លោះពី ៣៥០ លានដុល្លារ ដល់ ៥៥០ លានដុល្លារសហរដ្ឋអាមេរិក ឥឡូវនេះ កំពុងរៀបចំអភិវឌ្ឍន៍ឡើងវិញដោយក្រុមហ៊ុនអភិវឌ្ឍន៍ចិនឈ្មោះ យូ តៃ (Yue Tai)។ តំបន់ដីមាត់ទន្លេ កាលពីមុន ត្រូវបានប្រើប្រាស់ដោយទូកទេសចរណ៍ក្នុងស្រុក អ្នកលក់តាមដងផ្លូវ និងប្រជាពលរដ្ឋដែលចង់ហាត់ប្រាណ ឬសម្រាកលំហែ[30]។

ច្បាប់ភូមិបាលចែងយ៉ាងច្បាស់ថា ការចាត់ថ្នាក់ជាថ្មីនៃដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ (ដែលបន្ទាប់មកអាចលក់ទៅឱ្យអ្នកអភិវឌ្ឍន៍ឯកជន) អាចធ្វើទៅបាននៅពេលណាដីសាធារណៈរបស់រដ្ឋបាត់បង់ "ការប្រើប្រាស់ប្រយោជន៍សាធារណៈ"។ អ្វីដែលបានប្បញ្ញត្តិចំពោះការបាត់បង់ "ការប្រើប្រាស់ប្រយោជន៍សាធារណៈ" មិនមានចែងច្បាស់លាស់ទេ ហើយភាពចន្លោះប្រហោងមួយអាចងាយបង្កហានិភ័យដល់ដីសាធារណៈរបស់រដ្ឋទាំងអស់។ តាមការស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោត ដីមាត់ទន្លេមួយចំនួនត្រូវបាន ឬធ្លាប់ត្រូវបានប្រើប្រាស់ដោយសាធារណជនតាំងពីយូរមកហើយ សម្រាប់ប្រកបរបរលក់ដូរ សម្រាកលំហែ និងហាត់ប្រាណ។ ប៉ុន្តែ តាមផ្លូវច្បាប់ វាមិនច្បាស់លាស់ទេថាតើវាគឺជា "ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ" ដែរ ឬទេ។ របាយការណ៍នេះផ្តល់អនុសាសន៍ថា សិទ្ធិរបស់សាធារណជនក្នុងការប្រើប្រាស់ទីកន្លែងសាធារណៈត្រូវបានគោរពដោយចាត់វិធានការការស្រាវជ្រាវ និងពិនិត្យប្រកបដោយតម្លាភាពទៅលើអ្វីដែលជា "ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ។ ដោយគ្មានការយល់ដឹងច្បាស់អំពី "ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ" ផ្តល់ដោយរាជរដ្ឋាភិបាល ដីសាធារណៈរបស់រដ្ឋទាំងអស់នៅតែងាយប្រឈមហានិភ័យដោយសារការទិញលក់ និងការបាត់បង់ប្រយោជន៍សាធារណៈជាបន្តបន្ទាប់ដល់សាធារណជន។



*តាមបណ្តោយមាត់ទន្លេដែលប្រមូលផ្តុំដោយទូក អ្នកលក់គេសជ្ជៈ និងផ្សេងៗទៀត*
(អង្គការសមាគមធាងត្នោតឆ្នាំ២០១៨)

[30] Ibid footnote 10.

## សេចក្តីសន្និដ្ឋាន

របាយការណ៍នេះបានស្វែងរកចំនុចសំខាន់ៗ ដើម្បីផ្តល់ជូននូវរូបភាពច្បាស់ទាក់ទងនឹងស្ថានភាព នៅទីកន្លែងសាធារណៈក្នុងរាជធានីភ្នំពេញតាមរយៈ ការធ្វើផែនទី និងការសម្ភាសអ្នករស់នៅទីក្រុងដែល កំពុងប្រើប្រាស់ទីកន្លែងសាធារណៈទាំងនោះ។

លទ្ធផលរកឃើញបង្ហាញថា មានភាពមិន ស្របគ្នារវាងការប្រើប្រាស់ទីកន្លែងសាធារណៈដែល មាននៅក្នុងខណ្ឌខាងក្នុងក្រុង និងខណ្ឌខាងក្រៅក្រុង។ វាបានបង្ហាញផងដែរថា នៅពេលទីកន្លែងសាធារណៈ នៅក្នុងខណ្ឌខាងក្នុងក្រុង មានការប្រើប្រាស់ច្រើន ហើយអ្នកឆ្លើយតបបទសម្ភាសចង់បានទីកន្លែង សាធារណៈបន្ថែមទៀត និងជឿជាក់ថារាជរដ្ឋាភិបាល ជាអ្នកទទួលខុសត្រូវ ក្នុងការផ្តល់ទីកន្លែងសាធារណៈ ទាំងនោះ។ ផ្ទុយពីសេចក្តីចង់បាននេះ ករណីសិក្សា ថ្មីៗជាច្រើនបង្ហាញថារាជរដ្ឋាភិបាលបានចាត់ថ្នាក់ ជាថ្មីពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ ដោយគ្មានការប្រឹក្សាយោបល់ជាសាធារណៈដើម្បី បង្ហាញពីការបាត់បង់ "ការប្រើប្រាស់ជាប្រយោជន៍ សាធារណៈ"។ ករណីសិក្សាទាក់ទងនឹងដីមាត់ទន្លេ បង្ហាញថាទីកន្លែង សាធារណៈងាយស្រួលប្រគល់ឱ្យ ទៅវិស័យឯកជនណាស់ក្នុងលក្ខណៈមួយដែលផ្តល់ អាទិភាពដល់អាជីវកម្ម និងផលចំណេញជាជាងការ គិតពីទីតាំងរួមរបស់សាធារណជន។

ម្យ៉ាងវិញទៀត តួនាទីរបស់បុរីនៅក្នុងការ ផ្តល់ទីកន្លែងសាធារណៈ ជាការគួរឱ្យព្រួយបារម្ភ ដូច្នេះ វាគួរតែស្នើដល់រាជរដ្ឋាភិបាលឱ្យគិតពីតួនាទី របស់ខ្លួន ក្នុងការផ្តល់ទីកន្លែងសាធារណៈនៅក្នុងខណ្ឌ ខាងក្រៅក្រុង ដែលកំពុងត្រូវបានផ្តល់ដោយវិស័យ ឯកជនក្នុងកម្រិតគុណភាពទាប និងការចូលរួមតិច តួចពីសាធារណជន។ តាមការពិត អ្នកស្រាវជ្រាវទៅ ដល់ "ទីកន្លែងសាធារណៈ" ដើម្បីចាត់ថ្នាក់ទីកន្លែង សាធារណៈនោះជាថ្មី ព្រោះទីកន្លែងឯកជនបានក្លាយ ជានិន្នាការគួរឱ្យព្រួយបារម្ភសម្រាប់ប្រជាពលរដ្ឋរស់ នៅក្នុងរាជធានីភ្នំពេញ ហើយវាកាន់តែសំខាន់ជាងនេះ ទៅទៀតនោះគឺ ប្រសិនបើទីក្រុងចង់រីកលូតលាស់ និងអភិវឌ្ឍន៍ដោយរួមបញ្ចូលការធ្វើឱ្យមានទីកន្លែង ក្នុងទីក្រុងបន្ថែម។

ជាចុងក្រោយ អ្នកឆ្លើយតបសម្ភាសបាន លើកឡើងថាទីកន្លែងសាធារណៈបម្រើជីវភាពមួយ ផ្នែកធំ នៅក្នុងទីរាជធានីភ្នំពេញ ហើយបញ្ហានេះ តម្រូវឱ្យមានការយកចិត្តទុកដាក់ និងការស្រាវជ្រាវ បន្ថែមទៀតនាពេលខាងមុខ។ តួនាទីរបស់ទីកន្លែង សាធារណៈត្រូវធ្វើការសិក្សាក្នុងវិសាលភាពធំទូលាយ ដើម្បីធានាបានថាទីកន្លែងសាធារណៈទាំងនោះនៅ តែមានលក្ខណៈជាសាធារណៈយ៉ាងពិតប្រាកដ និង បម្រើប្រយោជន៍ដល់វិស័យ ឯកជន។ បច្ចុប្បន្ន មាន ការស្រាវជ្រាវបន្ថែមជាច្រើនទៀតទាមទារឱ្យធ្វើឡើង ទៅលើបញ្ហានេះ ក៏ប៉ុន្តែទិន្នន័យបង្ហាញយ៉ាងច្បាស់ថា មានការចង់បានទីកន្លែងសាធារណៈបន្ថែមទៀត និង ថានេះគឺជាតួនាទីរបស់រាជរដ្ឋាភិបាលនៅក្នុងការ បង្កើតបន្ថែម។

## អនុសាសន៍

១. ដំណើរការដោយតម្លាភាពមួយគួរត្រូវបាន ធ្វើឡើង និងអនុវត្តន៍តាម រួមមានការពិគ្រោះ យោបល់ជាសាធារណៈនៅពេលសម្រេចថាតើ ដីសាធារណៈរបស់រដ្ឋបានបាត់បង់ "ការប្រើប្រាស់ ជាប្រយោជន៍សាធារណៈ" ដែរ ឬទេ នៅក្នុង ការចាត់ថ្នាក់ជាថ្មីពីដីសាធារណៈរបស់រដ្ឋមក ជាដីឯកជនរបស់រដ្ឋស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។

២. ជំហានផ្សេងៗគួរត្រូវធ្វើឡើងដើម្បីធានាថា ទីតាំង និងព្រំប្រទល់នៃទីកន្លែងសាធារណៈមាន រួចរាល់សម្រាប់ការចូលប្រើប្រាស់ដោយងាយ ស្រួល។ ជំហានទាំងនេះមានដូចជា៖

ក) ការផ្សព្វផ្សាយតាមអនឡាញ និងផែនទី លម្អិតដែលបង្ហាញដីសាធារណៈរបស់ រដ្ឋនៅក្នុងរាជធានីភ្នំពេញ។

ខ) ដាក់សញ្ញាសម្គាល់ផ្លូវការនៅគ្រប់ទីកន្លែងសាធារណៈទាំងអស់ដែលបង្ហាញ ថាកន្លែងនោះជាទីសាធារណៈ។ នៅពេលដែលទីកន្លែងសាធារណៈមួយចំនួនដាក់សញ្ញាសម្គាល់បែបនោះរួចរាល់ហើយ គោលនយោបាយនោះគួរត្រូវអនុវត្តន៍យ៉ាងទូលំទូលាយដើម្បីលើកកម្ពស់តម្លាភាព។

៣. ទីកន្លែងសាធារណៈបន្ថែមគួរត្រូវបានបង្កើតឡើងទាំងនៅក្នុងខណ្ឌខាងក្នុងក្រុង និងខណ្ឌខាងក្រៅរាជធានីភ្នំពេញ ហើយអាជ្ញាធរគួរបញ្ចូលលទ្ធលទទួលបានពីការសិក្សានេះ ក៏ដូចជាដឹកនាំការស្រាវជ្រាវឱ្យបានទូលំទូលាជាងនេះទៀតអំពីអ្នកប្រើប្រាស់ទីកន្លែងសាធារណៈ ដើម្បីកំណត់ថាលក្ខណៈសម្គាល់ណាត្រូវបញ្ចូលក្នុងទីកន្លែងសាធារណៈថ្មីៗ។ ប្រភេទទីកន្លែងសាធារណៈថ្មីគួរមានដូចជា៖

ក) ទីកន្លែងដែលអាចគិតគូរដល់ទឹកជំនន់ជាប្រចាំនៅទីក្រុងភ្នំពេញ និងកម្រិតផលប៉ះពាល់នៃទឹកជំនន់នោះ ដូចមានឧទាហរណ៍នៃទីកន្លែងសាធារណៈនៅក្នុងទីក្រុងដូចជា កូប៉ែនហាហ្គេន (Copenhagen)[31] និង "ទីក្រុងដែលមានលក្ខណៈច្នៃប្រឌិតទប់ទល់នឹងទឹកជំនន់ (sponge cities)"[32]ដ៏ល្បីរបស់ប្រទេសចិន។

ខ) ទីកន្លែងដែលច្នៃប្រឌិត ដូចជាទីកន្លែងពេញនិយមប្រើប្រាស់ជាបណ្តោះអាសន្នកន្លែងប្រកួតប្រជែងនានា កន្លែងតូបតាមដងផ្លូវ និងកន្លែងសិល្បៈជាដើម។ កន្លែងទាំងនេះនឹងលើកកម្ពស់ការចូលរួមផុសផុលរបស់ប្រជាពលរដ្ឋនៅក្នុងការបង្កើតទីកន្លែងសាធាណៈ និងបង្កើតទីកន្លែងដែលបម្រើដល់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាអ្នកលក់តាមដងផ្លូវ ដែលជួនកាលត្រូវបានរារាំង ឬរើចេញពីទីកន្លែងសាធារណៈដទៃទៀត។

៤. ការស្រាវជ្រាវបន្ថែមគួរត្រូវធ្វើឡើងទាក់ទងនឹងទីតាំងល្អបំផុតនៃទីកន្លែងសាធារណៈថ្មី និងធ្វើការសិក្សាបន្ថែមទៅលើតំបន់ដែល បច្ចុប្បន្នកំពុងខ្វះទីកន្លែងសាធារណៈ ក៏ដូចជា ភាពអាចចូលបានជាសាធារណៈ ទៅក្នុងទីកន្លែងសាធារណៈដែលមានស្រាប់។

## ឯកសារយោង


Carmona, M., De Magalhaes, C., and Hammond, L., 2008, "Public Space: The Management Dimension". London, UK: Routledge.

Carr, S., Francis, M., Rivlin, L. G., and Stone, A. M., 1992. "Public Space". Cambridge, UK: Cambridge University Press.

Cathcart-Keays, A, 2016. "Why Copenhagen is building parks that can turn into ponds". Citiscope.

Crouch, D. P., 1981. "The historical development of urban open space". In L. Taylor, Urban Open Spaces. New York, NY: Rizzoli, 7–8.

Garret, B, 2010. "The privatisation of cities" public spaces is escalating. It is time to take a stand". Accessed at: https://www.theguardian.com/cities/2015/aug/04/pops-privately-owned-public-space-cities-direct-action

Goodsell, C, 2003. "The concept of public space and its democratic manifestations." The American Review of Public Administration 33.4 361-383.

"Green City Strategic Planning Methodology for Phnom Penh", 2016. Prepared by the National Council for Sustainable Development, the Royal Government of Cambodia, the Global Green Growth Institute and the International Centre for Environmental Management.

Holmes, 2017. "Death of democracy in Cambodia as court dissolves opposition". The Guardian.

Land Law, 2001. Cambodia.
Law on Peaceful Demonstrations, 2009. Cambodia.


[31] Cathcart-Keayes, 2016.

[32] Biswas and Hartley, 2017.

Németh, J., 2012. “Controlling the commons: how public is public space?”. Urban Affairs Review, 48(6), pp.811-835.

Peou, 2014. “Chroy Changvar Satellite City Construction Project Is In Progress”. Agence Kampuchea Presse.

Perry, 2016. “Copenhagen”s public spaces that turn into picturesque ponds when it rains”. The Guardian.

Rith, 2006. “Koh Pich holdouts yield to city landing force.” The Phnom Penh Post.

Smith, N. and Low, S. M., 2006, Introduction: The imperative of public space. In S. M. Low and N. Smith, editors, The Politics of Public Space. New York, NY: Routledge, 1–16.

Sokheng, 2010. “Freedom park inaugurated”. The Phnom Penh Post.

Springer, S, 2010. “Cambodia”s neoliberal order: Violence, authoritarianism, and the contestation of public space. Routledge”, 2010.

Springer, S, 2015. “Homelessness in Cambodia: the terror of gentrification”. In book: The Handbook of Contemporary Cambodia. Routledge.

Sub-Decree on Provisions and Procedures of Converting the State Public Properties and Public Legal Entities, 2006. No.129 ANRK/ BK. Royal Government of Cambodia.

Sun, 2017. “As gov”t prepares to shutter freedom park for good residents express mixed views on its legacy”. VOA Cambodia.

Taing and Marazzi Sassoon, 2018. “Unhappy Hour: Bars, other vendors cleared from Phnom Penh”s Wat Botum Park”. The Phnom Penh Post.

សមាគមធាងត្នោត

Sahmakum Teang Tnaut. a Cambodian Urban NGO